# សម្ភាសន៍ជាមួយ ស៊ឹម ចំរើន ភេទស្រី អាយុ៥៦ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ កងទ័ពនៅកងពល៩២០

## ស្រុកកំណើតនៅភូមិខ្នារទ្រនង់ ឃុំស្វាយរំពារ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

## រស់នៅភូមិព្រៃស្អាក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០១:៤៥:៤៧

## ៤៣ទំព័រ

ដានីៈ អីចឹងដំបូងមីងខ្ញុំសុំស្គាល់ឈ្មោះពេញ?

ចំរើនៈ ខ្ញុំ ស៊ឹម ចំរើន ។

ដានីៈ អាយុប៉ុន្មានហើយសព្វថ្ងៃ?

ចំរើនៈ ៥៦ ។

ដានីៈ ស្រុកកំណើតកើតជានៅណាដែរ?

ចំរើនៈ ភូមិខ្នារទ្រនង់ ឃុំស្វាយរំពារ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។ កាលពីខ្ញុំចេញមកវានៅក្នុងឃុំកក់ តែឥឡូវគេកាត់ទៅស្វាយរំពារ ។

ដានីៈ គ្រួសារមីងឈ្មោះអីដែរ?

ចំរើនៈ គ្រួសារខ្ញុំឈ្មោះ រស់ ដាន់ ។

ដានីៈ គាត់អាយុប៉ុន្មានហើយ?

ចំរើនៈ អាយុ៥៥ ។ គាត់នៅកំពង់ឆ្នាំង ។

ដានីៈ នៅខាងណាកំពង់ឆ្នាំង?

ចំរើនៈ ស្រុកបរិបូរណ៍ ភូមិថែងរស់ ។

ដានីៈ មីងសព្វថ្ងៃនៅក្នុងភូមិអីដែរ?

ចំរើនៈ ភូមិព្រៃស្អាក ឃុំត្រពាំងប្រាសាទ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

ដានីៈ មីងមានកូនចៅប៉ុន្មាននាក់ដែរ?

ចំរើនៈ ខ្ញុំកូន៦នាក់ ស្រី៤ ប្រុស២ ។

ដានីៈ ធំៗអស់ហើយ?

ចំរើនៈ ចា៎!

ដានីៈ គាត់រៀនសូត្រដល់ណាខ្លះដែរ?

ចំរើនៈ	កូនបង១ៗគេយកគ្រួសារ  នៅកូនពៅមួយរៀនចប់ថ្នាក់ទី១២ ។

ដានីៈ	បងៗរៀនចប់អស់ហើយ ។

ចំរើនៈ	ចា៎!  គេយកគ្រួសារហើយ  នៅពៅ ។

ដានីៈ	ពៅរៀនថ្នាក់ទី១២  អត់រៀនតទៅណាទៀតទេ?

ចំរើនៈ	អត់ទេ  គេរៀនជំនាញ  គេចង់រៀនកាត់ដេរ  កំពុងតែរៀន ។

ដានីៈ	មីងចាប់ផ្ដើមបំរើការងារតាំងពីឆ្នាំណាមក?

ចំរើនៈ	ខ្ញុំបើនិយាយពីការងារជំនាន់ហ្នឹងខ្ញុំចេញពីស្រុកឆ្នាំ៧៥ ។

ដានីៈ	ខ្ញុំចង់ដឹងឥឡូវតិច  ធ្វើការនៅខាងស្រុក ។

ចំរើនៈ	ខ្ញុំឆ្នាំ២០០៧ខ្ញុំជាសមាជិកក្រុមប្រឹក្សាឃុំ ។  ឆ្នាំ២០០៩  ខ្ញុំជាសមាជិកក្រុមប្រឹក្សាស្រុក

ដានីៈ	ឃុំត្រពាំងប្រាសាទ?

ចំរើនៈ	ចា៎!  ឃុំត្រពាំងប្រាសាទ  ឆ្នាំ២០០៩ចូលមកជាសមាជិកក្រុមប្រឹក្សាស្រុក ។

ដានីៈ	រហូតដល់ឥឡូវ?

ចំរើនៈ	ចា៎!

ដានីៈ	លោកពូមានធ្វើការនៅស្រុកដែរ?

ចំរើនៈ	គាត់មេភូមិព្រៃស្អាក ។

ដានីៈ	មីងបងប្អូនប៉ុន្មាននាក់ដែរ?

ចំរើនៈ	ខ្ញុំមានបងប្អូន៦នាក់  តែស្លាប់អស់ហើយ  នៅសល់៥ ។

ដានីៈ	ស្រីប៉ុន្មាន  ប្រុសប៉ុន្មានទៅ?

ចំរើនៈ	នៅប្រុស១  ស្រី៤ ។

ដានីៈ	ស្លាប់គាត់ស្រី  ឬប្រុស?

ចំរើនៈ	ប្រុស  ម៉ែខ្ញុំប្រុស២  ដល់មកខ្ញុំក៏ប្រុស២  ក្រកូនប្រុស ។

ដានីៈ	មីងកូនទីប៉ុន្មានដែរ?

ចំរើនៈ	ខ្ញុំកូនទី៥ហើយ  ខ្ញុំបន្ទាប់ពៅ ។

ដានីៈ	ឪពុកម្ដាយមីងគាត់នៅ  ឬខូចអស់ហើយ?

ចំរើនៈ	គាត់ស្លាប់អស់ហើយ ។

ដានីៈ	ឪពុកឈ្មោះអីទៅ?

ចំរើនៈ	ឈ្មោះ  ប៊ុន  ផា ។  ម្ដាយឈ្មោះ  អ៊ុង  ម៉ើ ។

ដានីៈ	កាលពីក្មេងៗមីងរៀនសូត្រដល់ណាដែរ?

ចំរើនៈ ខ្ញុំអត់បានរៀនដែរ ខ្ញុំរៀនបានថ្នាក់ទី១២ជំនាន់មុន ថ្នាក់ទី១២"ចាស់" ស្មើរថ្នាក់ទី២ឥឡូវ អត់ទេ ថ្នាក់ទី១១ ។

ដានីៈ មីងចេះអាន ចេះសរសេរទេ?

ចំរើនៈ បាន ដោយសារកាលខ្ញុំចូលធ្វើបដិវត្តន៍ហ្នឹង ចេះតែរៀនតាមម្លប់ឈើ ហើយទទួលយើងត្រូវដឹកនាំតូចតាចអីហ្នឹង ចេះតែរៀនៗទៅចេះអាន ចេះសរសេរមកទល់ឥឡូវ គេអត់ជឿថាខ្ញុំកំរិតវប្បធម៌ប៉ុណ្ណឹងទេ ។

ដានីៈ ថ្នាក់តិចពេកយើងចេះអាន ចេះសរសេរ?

ចំរើនៈ ថ្នាក់តិចពេក ដល់យើងធ្វើការកើត គេអត់ជឿ តែខ្ញុំនៅតែដាក់ប្រវត្តិខ្ញុំតែប៉ុណ្ណឹងដដែល ។

ដានីៈ មីងឈប់រៀនតាំងពីឆ្នាំណា?

ចំរើនៈ ឆ្នាំ៧៣រដ្ឋប្រហារ អត់មានគ្រូបង្រៀនទេ រត់ចោលអស់ហើយ៧៣ ។

ដានីៈ តែយើងរដ្ឋប្រហារតាំងពីឆ្នាំ៧០ ?

ចំរើនៈ ហ្នឹងហើយឆ្នាំ៧០រដ្ឋប្រហារហើយយើងនៅរៀនតាមភូមិ ដូចថាយើងរើសគ្រូបង្រៀនតាមភូមិ ៧៣ខ្ញុំឈប់ ។

ដានីៈ កាលនោះយើងរៀនមានសាលារៀន?

ចំរើនៈ អត់ទេ កាលពីមុនឆ្នាំ៧០រដ្ឋប្រហារយើងមាន ដល់ក្រោយមកយើងអត់មានគ្រូ ប្រជាពលរដ្ឋចេះតែចង់ចេះ រើសតំណាងខ្លួនឲ្យបង្រៀនតាមភូមិ ខ្ញុំចេះតែរៀនតិចៗអីចឹង ដល់យើងចូលចេះតែអាន ចេះសរសេរ ក៏អាចអានកើត សរសេរកើត ។

ដានីៈ ដល់មីងឈប់ឆ្នាំ៧៣ទៅធ្វើអីទៀតទៅ?

ចំរើនៈ ខ្ញុំឆ្នាំ៧៣កាលនោះខ្ញុំមិនទាន់ពេញវ័យយុវនារីទេ គេឲ្យជួយដឹកជញ្ជូន ជួយលើកទំនប់ប្រឡាយជំនាន់ហ្នឹង សែងរបួស ។

ដានីៈ កាលហ្នឹងយើងចូលជួរហើយ?

ចំរើនៈ ខ្ញុំនៅទេ ខ្ញុំនៅនារីភូមិ យើងជំនាន់នោះគេឲ្យធ្វើហើយ សូម្បីកុមារក៏ដោយ ។

ដានីៈ នៅខាងខ្នារទ្រនង់?

ចំរើនៈ ចាំ! លើកទំនប់ស្ទឹងកាត់ភ្លុក ។

ដានីៈ កាលហ្នឹងខាងកងទ័ពរំដោះចូលទៅដល់ហើយ?

ចំរើនៈ ចាំ! ចូលទៅដល់ហើយ តាំងពីរដ្ឋប្រហារភ្លាមនោះ ព្រោះអីយើងនៅជនបទដែរ ។

ដានីៈ តែយើងទៅដឹកជញ្ជូន នៅផ្ទះនៅឡើយទេ?

ចំរើនៈ នៅផ្ទះគេកេណ្ឌទៅ ។

ដានី៖ ឆ្នាំណាបានចេញ?

ចំរើន៖ ឆ្នាំ៧៥ បានខ្ញុំចេញមក ។

ដានី៖ ៧៥ ចេញទៅណា?

ចំរើន៖ ចេញកាលហ្នឹង ចេញពីស្រុកមកនៅមណ្ឌលគិរី ។

ដានី៖ ចេញពីផ្ទះមកទៅមណ្ឌលគិរីតែម្តង?

ចំរើន៖ ចា៎!

ដានី៖ ឆ្ងាយណាស់?

ចំរើន៖ កាលហ្នឹងយើងអាងជ័យជំនះហើយ៧៥ អីចឹងគេយកនារីដឹកជញ្ជូន យកកងនារីមក ខ្លះទៅស្រែអំបិល ខ្លះមករោងចក្រនៅភ្នំពេញ ដល់មកគេមានឲ្យនៅហ្នឹងណា៎ គេបញ្ជូនទៅខេត្តមណ្ឌលគិរី ទៅធ្វើកងទ័ពនៅនោះឯង ។

ដានី៖ ទៅធ្វើកងទ័ពនៅមណ្ឌលគិរីតែម្តង?

ចំរើន៖ ចា៎!

ដានី៖ ដំបូងមីងអត់ដឹងថាយើងចេញពីផ្ទះត្រូវទៅមណ្ឌលគិរីទេ?

ចំរើន៖ អត់ទេ គេថាយកមកភ្នំពេញធ្វើរោងចក្រ ។

ដានី៖ គ្នាច្រើនទេកាលហ្នឹងមក?

ចំរើន៖ គ្នាច្រើន និយាយទៅមើលមានខេត្តតាកែវ, កំពង់ស្ពឺ, សៀមរាប ៣ខេត្ត ។

ដានី៖ ខែប៉ុន្មានទៅដែលយើងចេញមក?

ចំរើន៖ ខែ១០ ។

ដានី៖ ខែ១០ បានចេញពីផ្ទះមក?

ចំរើន៖ ចា៎! ចេញពីស្រុកមកខែ១០ ឆ្នាំ៧៥ ។

ដានី៖ ដល់ពេលមកដល់ភ្នំពេញ?

ចំរើន៖ មកដល់ភ្នំពេញសំរាកភ្នំពេញបាន១យប់ ព្រលឹមឡើងគេឲ្យឡើងកប៉ាល់ទៅក្រចេះទៀត ។

ដានី៖ ឡើងកប៉ាល់ទៅជាមួយកងទ័ព?

ចំរើន៖ ទៅ ។

ដានី៖ កាលហ្នឹងកងទ័ពគេទៅជាមួយដែរ?

ចំរើន៖ អត់ទេ គេរើសតែកំលាំងនារី យុវជនដែលទៅថ្មីហ្នឹង ៣កប៉ាល់កាលហ្នឹងមនុស្សប្រហែលជាជិត១០០០នាក់ ។

ដានីៈ កាលហ្នឹងមីងមានអារម្មណ៍យ៉ាងម៉េចទៅ ដល់ពេលយើងធ្លាប់នៅស្រុកនេះ ស្រាប់តែទៅមណ្ឌលគិរី? កាលពីមុនដែលធ្លាប់ដឹង ធ្លាប់លឺពីមណ្ឌលគិរី?

ចំរើនៈ អត់ដែលដឹង លឺតែយាយតាគាត់ធ្លាប់ដំណាលថា នៅមណ្ឌលគិរីមានជនជាតិព្នង ប្រហោងទ្រូង ស៊ីកូនឯង ដល់ពេលទៅវាអត់ឃើញមាន វាព្នងមែន គ្រាន់តែកាលហ្នឹងវាមានការអប់រំពីថ្នាក់ដឹកនាំ ចេះស្លៀកពាក់ខោអាវដូចយើងធម្មតា តែពីមុនគ្រាន់តែលឺទេ ។ ខ្ញុំទៅនៅក្រចេះបាន៣ខែបានគេបញ្ជូនទៅមណ្ឌលគិរីទៀត ។

ដានីៈ អីចឹងចេញទៅដំបូង នៅភ្នំពេញបាន៣ថ្ងៃ ។

ចំរើនៈ ចេញពីវ៉ារទេះភ្លើងយប់ហ្នឹងសំរាកយប់ហ្នឹងមួយយប់ ព្រលឹមឡើងចុះកប៉ាល់ទៅក្រចេះទៀត សំរាកភ្នំពេញបាន១យប់ ។ ទៅនៅក្រចេះបាន៣ខែ បានគេបញ្ជូនទៅមណ្ឌលគិរី ។

ដានីៈ ធ្វើអីទៅនៅក្រចេះ?

ចំរើនៈ នៅក្រចេះជួយលើកទំនប់ប្រជាជននៅក្រចេះហ្នឹង ជួយលើកទំនប់ ។ កាលនោះដោយសារខ្ញុំទៅឆ្ងាយឆ្នាំ៧៩ដែលយួនចូលស្រុក បើសិនជានៅជិតៗនឹងគេក៏ខ្ញុំទៅផ្ទះដែរ ដល់ឆ្ងាយពេក ។ កាលយើងទៅគេបញ្ជូនទៅតាមកប៉ាល់ តាមឡាន ដល់មកវិញមិនដឹងមកផ្លូវណាខ្លាចវាមកមិនដល់ ព្រោះអីឃើញគេអ្នករត់មកដែរ ដល់ក្រចេះគេចាប់បញ្ជូនទៅវិញ អីចឹងក៏ចេះតែទ្រាំនៅនឹងគេឯងទៅ ។

ដានីៈ កាលហ្នឹងយើងភ័យព្រួយដែរ?

ចំរើនៈ ភ័យព្រួយ ភ័យខ្លាចដែរ ធម្មតាការបែកពីស្រុកវាឆ្ងាយ យើងមិនដែលដឹងលឺពីស្រុកគេ ហើយម្យ៉ាងទៅនៅហ្នឹងជនជាតិខុសគ្នាទៀត យើងខ្មែរ នោះព្នង ។

ដានីៈ តែមកពីភូមិយើងមានប៉ុន្មាននាក់ដែលទៅជាមួយ?

ចំរើនៈ ដែលទៅជាមួយខ្ញុំពីរនាក់បងប្អូនបង្កើត ហើយ៣នាក់នៅក្នុងភូមិជាមួយខ្ញុំ ។

ដានីៈ អ៊ូ! បាន២នាក់បងប្អូនបង្កើត!

ចំរើនៈ បាន២នាក់បងប្អូនបង្កើតដែរ ។

ដានីៈ ស្រី ឬប្រុស?

ចំរើនៈ ស្រី ។

ដានីៈ ស្រីដូចគ្នា?

ចំរើនៈ ចា៎!

ដានីៈ បន្ទាប់?

ចំរើនៈ បងបន្ទាប់ខ្ញុំ កាលនៅផ្ទះហ្នឹងគាត់នៅកងនារី ខ្ញុំនៅដឹកនាំកុមារនៅភូមិទេ ដល់ពេលគេរើសទៅជួបគ្នានៅវ៉ារទេះភ្លើង បានដឹង ។

ដានីៈ គាត់ឈ្មោះអីដែរ?

ចំរើនៈ គាត់ឈ្មោះ ស៊ីម ឃិន ឥឡូវគាត់នៅនេះដែរ ។

ដានីៈ មកនៅហ្នឹងដែរ?

ចំរើនៈ ចា៎! ចូលមកនៅនេះដែរ បាន២នាក់បងប្អូន ដល់ពេលទៅដល់មណ្ឌលគិរី ក្រចេះហ្នឹងក៏គេអត់ឲ្យនៅជាមួយគ្នា គេបំបែក ទៅមណ្ឌលគិរីទៀតក៏អត់ឲ្យនៅជាមួយគ្នាដែរ ។ បងខ្ញុំនៅកោះយើល ខ្ញុំនៅកោះញែក បំបែកគ្នា ។

ដានីៈ អីចឹងពេលទៅដល់៣ខែទៅបានទៅមណ្ឌលគិរី?

ចំរើនៈ ចា៎!

ដានីៈ ជិះអីទៅមណ្ឌលគិរី?

ចំរើនៈ ជិះឡានយើងអាតុងហ៊្វីង ក្បួនឡាន១២គ្រឿង ដឹកទៅនារី-យុវជន ។

ដានីៈ ១២គ្រឿង?

ចំរើនៈ ចា៎! ទៅហ្នឹងទៅនៅក្នុងព្រៃអត់មានភូមិទេ យកទៅដាក់ក្នុងព្រៃតាមមាត់អូរច្បារឲ្យយើងលើកភ្លឺស្រែ បង្ករបង្កើតធ្វើជាភូមិ ។

ដានីៈ កាលហ្នឹងមីងទៅនៅជាមួយខាងកងទ័ព ឬនៅជាមួយខាងប្រជាជន?

ចំរើនៈ កងទ័ពនៅកងពល៩២០ ។

ដានីៈ នៅកងពល៩២០?

ចំរើនៈ ចា៎!

ដានីៈ កងពល៩២០ចេញពីកំពង់ស្ពឺមកឬយ៉ាងម៉េចខ្ញុំអត់សូវច្បាស់?

ចំរើនៈ អត់ទេ ចេញពីកំពង់ស្ពឺមកយើងជាទ័ពតំបន់ទេ ដល់ពេលទៅនៅក្រចេះគេបញ្ចូលទៅកងពល៩២០ ទាំងនារីយុទ្ធជនដែលទៅទាំងប៉ុន្មាននាក់ហ្នឹង ។

ដានីៈ នៅកងពល៩២០?

ចំរើនៈ ចា៎! ហើយដល់ឆ្នាំ៧៦គេកាត់ពួកខ្ញុំឲ្យទៅនៅតំបន់មណ្ឌលគិរី ។

ដានីៈ អីចឹងដំបូងនៅកន្លែងកងពល៩២០?

ចំរើនៈ ចា៎!

ដានីៈ មីងមានប្រសាសន៍ថាមានបែងចែកគ្នាទៀត ដូចថាបងស្រីគាត់ទៅនៅខាងកោះយើល ។

ចំរើនៈ ខ្ញុំនៅខាងស្រុកកោះញែក ។

ដានី៖ មីងនៅកងណាទៅ ដល់ពេលយើងនៅបែកគ្នាអីចឹង? ៩២០មានកងតាមវរៈ?

ចំរើន៖ មានតាមវរៈទៀត កាលហ្នឹងខ្ញុំមិនដឹងវរៈប៉ុន្មានទេ កងវរៈខ្ញុំប្រធានឈ្មោះរ៉ុ ។

ដានី៖ វរសេនាតូច ឬវរសេនាធំ?

ចំរើន៖ វរសេនាតូចទេ ឈ្មោះរ៉ុ ។ ប្រហែលជាវរសេនាធំដឹងព្រោះអីមានពាកង ។ ប្រហែលជាអនុសេនាតូចទេកាលនោះ តែមិនដឹងជាលេខប៉ុន្មានទេ ដឹងតែបញ្ជាការខ្ញុំឈ្មោះ រ៉ុ កងវរៈ

ដានី៖ ខាងកងពលគេពីណាគេអ្នកដឹកនាំ?

ចំរើន៖ កងពលកាលនោះ ប្រធានកងពល ឈិន នោះ ។

ដានី៖ បាទ! លឺឈ្មោះគាត់ ។

ចំរើន៖ ឈិន ហើយនិង សយ ។ ដល់ឆ្នាំ៧៧គេចាប់ពួកហ្នឹង ។

ដានី៖ ៧៧គេចាប់?

ចំរើន៖ បាទ! ចាប់ឈិន និងសយ ហ្នឹងទៅ បាននៅតាសាន ។

ដានី៖ តាសាន ចូលមក!

ចំរើន៖ តាសាន ចូលមក ហើយក៏គេកាត់ពួកខ្ញុំទៅនៅតំបន់មណ្ឌលគិរីវិញ ទៅឲ្យទ័ពតំបន់វិញ ។

ដានី៖ ម៉េចបានគេកាត់អីចឹង?

ចំរើន៖ កាលហ្នឹងមិនដឹងជាយ៉ាងម៉េច គេគិតថាគេសង មិនដឹងជាយ៉ាងម៉េច ពួកខ្ញុំវេទនាណាស់ ហើយនៅកងពល៩២០ហូបមិនដែលឆ្អែតទេ ដល់បានគេកាត់ឲ្យទៅខាងកងតំបន់មណ្ឌលគិរីវិញហ្នឹងបានហូបគ្រប់គ្រាន់ លែងអត់ឃ្លានហើយ ។

ដានី៖ អត់បាននៅជាមួយ តាសាន ទេ?

ចំរើន៖ អត់ទេ ចេញពីតាសាន និយាយទៅកាលជំនាន់ហ្នឹងនៅជាមួយ ឈិន និងសយ អត់ដែលបានបាយហូបគ្រប់ទេ សំរាប់អ្នកជាបានបាយមួយចាន គេដួសទុកស្រេចៗលើតុ យើងឡើងពីធ្វើការមកគេដួសទុកឲ្យ តែអ្នកឈឺ បើទៅហូបនៅសហករណ៍បានអាហ្នឹងបានបបរ៣វែក តែបើអ្នកទៅមិនរួចឈឺដេក ឲ្យគេយកផ្ញើរបានតែមួយវែក ហ្នឹងជំនាន់ហ្នឹង ។ ក្រោយមកគេចាប់ពួកហ្នឹងអស់ ដូចជារាងគ្រាន់ដែរ ហូបចុកបានគ្រប់គ្រាន់ទៅ ជំនាន់តាសាន ចូលកាន់កាប់ហ្នឹង គាត់គ្រប់គ្រង ។

ដានី៖ ឈិន និងសយ ស្គាល់គាត់ច្បាស់ទេ?

ចំរើន៖ ស្គាល់ថាគាត់ជាប្រធានកងពលហើយ តែកាលហ្នឹងគេថាខ្មែរវៀតណាម ហើយគាត់បង្រៀនពួកខ្ញុំក៏គាត់និយាយដែរ គាត់ថា ហ្នឹងខ្ញុំនិយាយតាមឯកសារគេបង្រៀនជំនាន់នោះ ៧៥-៧៦ហ្នឹង គេថាវៀតណាមនៅតែចង់លេបត្របាក់ទឹកដីខ្មែរជារៀងរហូត ទោះបី

ជំនាន់នេះមិនបាន ដល់ជំនាន់កូនក្រោយទៀត ក៏នៅតែចង់លេបទឹកដីៗ ហើយអ្នកដែលបង្រៀនហ្នឹងពួកហ្នឹ ឈិន, សយ ។ ដល់រយៈក្រោយមកឆ្នាំ៧៧ស្រាប់តែលឺគេចាប់ថាពួកហ្នឹងក្បត់ ហ្នឹងតាមតែខ្ញុំដឹងទេ ។

ដានី: ចាប់តែគាត់២-៣នាក់?

ចំរើន: កាលហ្នឹងចាប់ដល់វរសេនាធំទៀត ។ ហ្នឹងខ្ញុំមកនៅកងទ័ពតំបន់ហើយ ។

ដានី: បានតាសាន ចូលទៅបាននៅជាមួយ តាសាន ខ្លះដែលអត់?

ចំរើន: អត់ទេ តាសាន ចូលទៅខ្ញុំចេញមកតំបន់ហើយ គ្រាន់តែថាពេលដែលគេចាប់ពួកហ្នឹង ខ្ញុំនៅទ័ពតំបន់ខ្ញុំនៅយាមពួកហ្នឹងឯង គេចាប់យកមកដាក់នៅកន្លែងតំបន់ ហើយកាលហ្នឹងខ្ញុំនៅទ័ពតំបន់ គេឲ្យគ្រប់គ្រងយាមពួកហ្នឹង ។

ដានី: យាមពួក ឈិន, សយ ហ្នឹង?

ចំរើន: ហ្នឹងហើយ ពួកវរសេនាតូច, វរសេនាធំដែលគេចាប់មក គេចាប់យកមកដាក់នៅកន្លែងតំបន់ ។ តាសាន ចូលមកគ្រប់គ្រងហ្នឹង អ្នកដែលនៅដូចថាយើងស្គាល់គ្នានៅកងពលចាស់សួរទៅឥឡូវម៉េចដែលហួបចុកអី ថាអត់អីទេគ្រប់គ្រាន់ ។

ដានី: មីងមកខាងតំបន់នៅកន្លែងសន្តិសុខ?

ចំរើន: ចា៎! ខ្ញុំនៅកងទ័ពតំបន់ កាលហ្នឹងគេមានកងតំបន់ ។

ដានី: កងតំបន់មណ្ឌលគិរី?

ចំរើន: ចា៎! មណ្ឌលគិរីហ្នឹង ខ្ញុំនៅវរៈទី២ ។

ដានី: តំបន់មណ្ឌលគិរីហៅតំបន់លេខប៉ុន្មាន?

ចំរើន: មិនដឹងលេខប៉ុន្មានទេកាលនោះភ្លេចទៅហើយ គេហៅកងតំបន់ បើកងពល៩២០ឈរជើងនៅហ្នឹង ហើយតំបន់មិនដឹងលេខប៉ុន្មាន កាលនោះគេហៅតែកងតំបន់ៗ ព្រោះអីតំបន់វាមានតែមួយហ្នឹង ។

ដានី: មានតែមួយ អត់ចូលជាមួយភូមិភាគទេ?

ចំរើន: អត់ទេ ។

ដានី: ដាច់ហើយ តំបន់ពិសេស តំបន់ស្វយ័ត?

ចំរើន: ចា៎! គ្រាន់តែការទៅធ្វើការ ទៅត្រៀម ខ្សែត្រៀមតាមព្រំដែនគ្រាន់ធ្វើការវាជាប់គ្នាប៉ុណ្ណឹងទេ ។

ដានី: កាលហ្នឹងប្រធានតំបន់ពីណាគេ?

ចំរើន: ប្រធានតំបន់ តាហម ខ្មោចអ៊ឹហម ។

ដានី: តាហម, តាឡាំង?

ចំរើន: ចា៎! ហ្នឹងហើយតាឡាំង ដែលគាត់ស្លាប់ដោយសារស្នាដៃ កំភួន មុនដំបូង កំភួនហ្នឹងឯង ។

ដានី: កំភួន ហ្នឹងធ្វើអីគេ?

ចំរើន: កំភួន ហ្នឹងក៏គណៈតំបន់ដែរ តែក្រោមគាត់ ។

ដានី: អនុ តាកំភួន?

ចំរើន: ចា៎!

ដានី: តាហ្នឹងយ៉ាងម៉េចមីងដឹងរឿងដែលគាត់ ដូចថាមិញមីងថាតាឡាំង ស្លាប់ក្រោម?

ចំរើន: ថ្ងៃដែលគាត់ស្លាប់ខ្ញុំនៅមន្ទីរគាត់ គាត់គ្រប់គ្រងកងទ័ពនៅភ្នំក្រោលហ្នឹងឯង ដល់ថ្ងៃហ្នឹងពួកខ្ញុំគាត់ឲ្យយកឡានមួយទៅយកត្រីនៅព្រំដែនកង់ឡែ ហើយកំភួន ហ្នឹងគេចោទថាចូលយួនដែរ ដល់អីចឹងគេចាប់យកទៅឃុំឃាំង ដល់ពេលថ្ងៃគាត់ស្លាប់ថាមកភ្នំពេញ ពួកខ្ញុំអត់នៅខ្ញុំទៅកង់ឡែទៅថាគាត់មកភ្នំពេញ ថាមកកន្លែងធ្វើការគាប៉ុល ពត ហើយស្លាប់នៅភ្នំពេញទេ ។

ដានី: តាឡាំង, តាហមហ្នឹង គាត់ភ្នំពេញ ហើយតាកំភួន មកភ្នំពេញដែរ?

ចំរើន: មកដូចថាគេយកមកដោះស្រាយគ្នានៅកន្លែងគេធ្វើការ កន្លែងអ្នកធំៗគេធ្វើការ ដល់ពេលសំភាកហ្នឹងតាមខ្ញុំដឹងនីរសាគាត់និយាយព្រោះខ្ញុំនៅមន្ទីរហ្នឹង គាត់ថាទៅសំភាកហ្នឹងបន្ទប់មួយម្នាក់ ។ កំភួន ហ្នឹងបន្ទប់មួយ តាឡាំង បន្ទប់មួយ ដល់យប់ឡើងកំភួន ដកចម្រឹងបង្គួច វៃតាឡាំង ស្លាប់នៅហ្នឹងឯង ។

ដានី: ដកចម្រឹងបង្គួចវៃតាឡាំង ហើយតាកំភួន ម៉េចទៅគេចាប់?

ចំរើន: ចាប់ ។

ដានី: ឆ្នាំណាហ្នឹង?

ចំរើន: ឆ្នាំដូចជា៧៨ ។

ដានី: ឆ្នាំ៧៨ហើយ?

ចំរើន: ចា៎! ៧៨ហើយ ៧៩ខ្ញុំចេញពីនោះហើយ ។

ដានី: យូរប៉ុណ្ណាប់ដែលគាត់គេវៃស្លាប់ ប្រហែលរយៈពេលប៉ុន្មានបានបែក យួនចូល?

ចំរើន: យូរដែរហ្នឹង តាំងពីអ៊ំឡាំង ស្លាប់ទៅសភាពការណ៍ចេះតែរំដើបរំជួលរហូត ឆ្នាំ៧៩ខែប៉ុន្មានទេ ខ្ញុំមិនសូវចាំដែរ វៀតណាមចូលដល់ ។

ដានី: ខាងកងទ័ពតំបន់ពីណាគេធ្វើប្រធាន?

ចំរើនៈ កងទ័ពហ្នឹងកាលនោះមានវរៈ តាអីទេភ្លេចឈ្មោះ ខ្ញុំស្គាល់តែវរសេនាតូច ឈ្មោះផាំង, មាំង វរសេនាធំ ហើយតាវៀង សុទ្ធតែកងវរៈ ។

ដានីៈ តាខាំ វៀង?

ចំរើនៈ ចា៎! ខាំ វៀង ហ្នឹងហើយ ។ ហើយតាមាំង, តាផាំង សុទ្ធតែកងវរៈហើយ ។

ដានីៈ ក្រុមរបស់មីងគេដកឲ្យមកនៅក្រោមពួកគាត់វិញ?

ចំរើនៈ ចា៎! ដល់ពេលហ្នឹងមកខ្ញុំមកនៅក្នុងវរៈតាមាំង រហូតដល់ពេលរត់ចេញមក ៧៩ ។

ដានីៈ កាលជិនាន់ហ្នឹងអ្នកចូលដៃជាមួយយួន គេចាប់មកទុកកន្លែងតំបន់?

ចំរើនៈ ចា៎! គេយកមកកន្លែងតំបន់ហ្នឹងឯង ។

ដានីៈ តំបន់ហើយបានគេបញ្ជូនមកទៀត?

ចំរើនៈ បានដាក់ឡានមកភ្នំពេញ ។

ដានីៈ តាឡាំង, តាកំភួន ពីរនាក់គាត់បាត់ពីណាឡើងជាតំបន់ជំនួស?

ចំរើនៈ កាលខ្ញុំនៅហ្នឹងមានប្រពន្ធគាត់ ប្រពន្ធតាឡាំង ។

ដានីៈ គាត់ឈ្មោះអីប្រពន្ធ?

ចំរើនៈ ឈ្មោះភា ធ្លាប់ហៅគាត់តែម៉ែមុំៗ ។ ប្រហែលជាឈ្មោះភា ។

ដានីៈ គាត់ជនជាតិដែរ?

ចំរើនៈ គាត់ខ្មែរ តែគាត់ទៅនៅស្រុកនោះយូរហើយ ហៅតែបងម៉ែមុំៗហ្នឹងឯង ។ យើងគ្រាន់តែនេះហើយអត់បានមួយឆ្នាំផង យើងរត់បែកគ្នា ។

ដានីៈ អត់មានពីណាមកជំនួសគាត់ទេ?

ចំរើនៈ ចា៎! អត់ទាន់មានទេ ឬក៏ខ្ញុំដឹងមិនអស់មិនដឹង តាមតែខ្ញុំចាំ ។

ដានីៈ ដល់ពេលឆ្នាំ៧៩ម៉េចទៀតទៅ?

ចំរើនៈ ៧៩ហ្នឹងផ្ទៃក្នុង រឿងគេនេះហ្នឹងវាអស់ហើយ អត់មានគេចាប់យកមកដាក់ទៀតទេ ដល់សភាពការណ៍អត់ស្រួលបំបែកគ្នានៅខ្សែត្រៀមទាំងយប់ ទាំងថ្ងៃ នៅខ្សែត្រៀមរហូតលុះដល់ថ្ងៃគេរំដោះបានហ្នឹង បានចេញពីខ្សែត្រៀម ចេញពីមូលដ្ឋានទៅព្រៃ ចេញពីកោះញែក ។

ដានីៈ អីចឹងដល់ពេលយួនចូលឆ្នាំ៧៩ ទៅកោះញែកវិញ?

ចំរើនៈ ខ្ញុំនៅហ្នឹងឯង នៅកោះញែក ដល់ពេលហ្នឹងនាំគ្នាចេញ ចេញពីស្រុកទៅចូលព្រៃ ទៅនៅក្នុងព្រៃ ។

ដានីៈ ទៅនៅព្រៃនៅណា?

ចំរើនៈ    កាលនោះគេហៅព្រៃមីមោង ហ្នឹងព្រៃចាក់តែម្ដងអត់ឃើញពន្លឺថ្ងៃទេ ដល់ពេលវៀតណាមចូលដល់ទីរួមស្រុកកោះញែកហ្នឹង ប្រជាពលរដ្ឋហ្នឹងអ្នកណាដែលគេនេះគេនៅភូមិទៅ ដូចយើងទៅពីចំងាយអីចេះយើងអត់ទុកចិត្តប្រជាពលរដ្ឋ ខ្លាចគាត់រាយការណ៍ យើងចេះតែទៅតាមកងកំលាំងគេហ្នឹងរហូត យើងអត់ទុកចិត្ត ។

ដានីៈ    ចេញពីហ្នឹងទៅណាទៀត?

ចំរើនៈ    ចេញពីហ្នឹងមកនៅព្រៃរហូតលុះដល់ឆ្នាំ៨១ ។

ដានីៈ    ព្រៃនៅណា?

ចំរើនៈ    ព្រៃនៅមណ្ឌលគិរីហ្នឹងឯង នៅក្នុងព្រៃ ។

ដានីៈ    នៅក្នុងខេត្តមណ្ឌលគិរីហ្នឹងដែរ?

ចំរើនៈ    ចា៎! នៅក្នុងខេត្តមណ្ឌលគិរី ។

ដានីៈ    រហូតដល់ឆ្នាំ៨១?

ចំរើនៈ    ឆ្នាំ៨០-៨១បានមកនៅក្រចេះ តែនៅព្រៃដែរ ហូបក្លូច ។

ដានីៈ    កាលហ្នឹងមីងនៅក្នុងកងទ័ពតំបន់ដដែល ឬចូលក្នុងកងពលអីវិញហើយ?

ចំរើនៈ    នៅក្នុងកងតំបន់ ។

ដានីៈ    ពីណាគេអ្នកដឹកនាំក្នុងព្រៃ?

ចំរើនៈ    គ្រប់គ្រងពួកខ្ញុំហ្នឹង កាលហ្នឹងនៅតាផាំង ហើយតានូ ។ គ្រប់គ្រងពួកខ្ញុំ គ្រប់គ្រងមីងៗ ។

ដានីៈ    ចុះតាសារុន?

ចំរើនៈ    តាសារុន អស់ពីនេះទៅមានតាសារុន ខ្ញុំភ្លេច ។

ដានីៈ    អត់ពីអ្នកណា?

ចំរើនៈ    អត់ពីតាឡាំង មានតាសារុន គាត់ឡើង ។

ដានីៈ    តាសារុន ណា?

ចំរើនៈ    តាសារុន ហ្នឹង មិនដឹងគាត់ស្លាប់ ឬគាត់នៅ ។

ដានីៈ    ខ្ញុំធ្លាប់ជួបគាត់ គាត់នៅ ។

ចំរើនៈ    ចា៎! មានតាសារុន ហ្នឹងឯង ។

ដានីៈ    តាសារុន, តាអម ស៊ុំ ។

ចំរើនៈ    ហ្នឹងហើយខ្ញុំភ្លេច ។

ដានីៈ    អត់ពីតាឡាំង, តាកំភួន ទៅសារុន ឡើង?

ចំរើនៈ    ហ្នឹងឯងគាត់ឡើង ។

ដានី: ដល់ពេលនៅក្នុងព្រៃរហូតដល់ឆ្នាំ៨១ បានមីងមកដល់ក្រចេះ?

ចំរើន: ៨១ បានខ្ញុំឡើងភ្នំដងរែក ។

ដានី: ៨១ បានឡើង?

ចំរើន: ចា៎! ហូបក្តួច ខ្ញុំហូបក្តួច២ឆ្នាំគត់ ។

ដានី: ជួបបងស្រីដែលពេលនៅក្នុងព្រៃ?

ចំរើន: ជួបកាលពីបែកចេញពីកោះញែកមកជួបគ្នា បានបន្តិចគេឲ្យបំបែកគ្នាទៀត ខ្ញុំនៅកងនារីដឹកជញ្ជូន គាត់គេឲ្យនៅតាមមីង១គាត់មានគ្រួសារ ។

ដានី: កាលមីងមកនៅកងតំបន់ គាត់នៅកងតំបន់ដែរ?

ចំរើន: ចា៎! នៅកងតំបន់ដែរ ។

ដានី: នៅអង្គភាពជាមួយគ្នា?

ចំរើន: ចា៎! អង្គភាពជាមួយគ្នា និយាយទៅ៧៦-៧៧-៧៨-៧៩ គាត់រៀបគ្រួសារខ្ញុំនៅលីវ ដល់ពេលយើងរត់ចូលព្រៃ គេបំបែកអ្នកលីវឲ្យដឹកជញ្ជូនផ្សេង អ្នកមានគ្រួសារនៅជាមួយមីង១ផ្សេង ទើបមកជួបគ្នានៅលើភ្នំឆ្នាំ៨៣ ។

ដានី: ពេលដែលឆ្នាំ៨១ យើងរត់មកដល់ក្រចេះ ហ្នឹងឆ្លងទឹកមកអត់?

ចំរើន: ឆ្លងទឹក ។

ដានី: បានអីឆ្លងទៅ?

ចំរើន: មកទន្លេខ្លះតូចក៏ហែលទៅ ទន្លេធំក៏ជិះទូក ។

ដានី: បើទន្លេធំយើងជិះទូក?

ចំរើន: ចា៎! កាលនោះគេវៃតាមផ្លូវរហូត អាឆ្លងទន្លេហ្នឹងយើងឆ្លងរួចម៉ោង៤ យើងផុតអីចឹងគេមកពីក្រោយ និយាយទៅរត់រហូតបើផ្លូវជាតិលេខ៦សឹងតែថាជាន់បាន១ជំហាន រត់ឲ្យតែកន្លែងផ្លូវរត់ហើយអត់ដែលបានដើរទេ ។

ដានី: ឆ្លងពីមណ្ឌលគិរីមកក្រចេះកន្លែងណា ម្តុំណា?

ចំរើន: ទៅឆែប ។

ដានី: ផ្លូវឆែប?

ចំរើន: ចា៎!

ដានី: ឆែបខាងព្រះវិហារ?

ចំរើន: ព្រះវិហារ ។

ដានី: មិនមែនក្រចេះទេ?

ចំរើន: មកពីនោះមកនៅតាមព្រៃនៅតំបន់ក្រចេះ នៅព្រៃអត់មានស្បៀងយើងរកព្រៃណាមានក្តួច មានដំឡូងចេះតែស្នាក់នៅត រហូតមកដល់ព្រះវិហារមកឆ្លងផ្លូវផែប ។

ដានី: យ៉ាងម៉េចតទៀតទៅមកដល់ផែប?

ចំរើន: ឆ្លងមកអីចឹងទៅខ្វះក៏ដាច់ស្បៀង អ្នកឈឺនៅក្រោយ អ្នកមានកំលាំងទ័ពគេចេះតែនាំមកៗ ឡើងដល់ទន្លេល្ពៅ ហ្នឹងបានអន្តរហូបនៅទន្លេល្ពៅហ្នឹងឯង ។

ដានី: ឆ្នាំណាមកដល់ទន្លេល្ពៅ?

ចំរើន: ឆ្នាំ៨១ ។

ដានី: ឆ្នាំ៨១មកដល់ទន្លេល្ពៅ?

ចំរើន: ចា៎! ទន្លេល្ពៅហៅមុំ៣ ជាប់ដីលាវហ្នឹង ។

ដានី: កន្លែងទន្លេល្ពៅ កន្លែងមុំ៣?

ចំរើន: ចា៎! មកនៅហ្នឹងឯង ។

ដានី: ឡើងលើភ្នំហ្នឹងតែម្តង?

ចំរើន: ឡើងនៅលើភ្នំហ្នឹងឯង ឆ្នាំ៨១-៨៤ទើបចេញពីហ្នឹងទៀត ។

ដានី: ឆ្នាំ៨១ទៅដល់ទន្លេល្ពៅ ទៅដល់ហ្នឹងឃើញមនុស្សច្រើននៅ?

ចំរើន: មានហើយ ព្រោះអីកាលហ្នឹង តាខៀវ គាត់មកនៅ គាត់ទាក់ទងតាមរយៈដីថៃ ដឹកស្បៀងតាមថៃហ្នឹងឯង ។

ដានី: ពេលមីងមកដល់ តាខៀវ នៅហ្នឹង?

ចំរើន: ចា៎! តាខៀវ នៅហ្នឹង ។

ដានី: តាៗផ្សេងទៀតមាននៅហ្នឹងដែលអត់?

ចំរើន: អត់ទេ នៅតែអ៊ំខៀវទេ តាម៉ុក គាត់នៅខាង១០០៣ ។ ពួកខ្ញុំគេហៅ១០០១ ។

ដានី: ហ្នឹង១០០១?

ចំរើន: ១០០១ ។

ដានី: អីចឹងឡើងទៅដល់កន្លែងហ្នឹង១០០១?

ចំរើន: ចា៎!

ដានី: កាលហ្នឹងមីងធ្វើអីទៅពេលមកដល់ហ្នឹង?

ចំរើន: ខ្ញុំនៅដឹកជញ្ជូន នៅកងនារីដឹកជញ្ជូនដែរ ។

ដានី: ឈប់ធ្វើកងទ័ពហើយ?

ចំរើនៈ ឈប់ហើយ ដឹកជញ្ជូនពីលើភ្នំ ដើបព្រឹកឡើងជញ្ជូនគ្រាប់ចុះ ឡើងមកវិញសែងរបួសឡើង រាល់ថ្ងៃអីចឹង ជញ្ជូនគ្រាប់, ជញ្ជូនអង្ករ, មីន ព្រឹកឡើងចុះ ថ្ងៃឡើង ។

ដានីៈ ដឹកជញ្ជូនគ្រាប់មកឲ្យកងទ័ព?

ចំរើនៈ មកឲ្យកងទ័ពម្ដុំវាលវៀស ម្ដុំអូរជុចនេះ ។

ដានីៈ កងទ័ពរបស់តំបន់?

ចំរើនៈ កងទ័ពខ្មែរក្រហម ។

ដានីៈ តែពេលយើងមកដល់ ។

ចំរើនៈ ទៅដល់ហ្នឹងអត់មានតំបន់ទេ កងពលហើយ ចូលក្នុងកងពលទាំងអស់ ។

ដានីៈ តែមីងឈប់នៅកងពលហ្នឹងហើយ?

ចំរើនៈ ចា៎! នៅកងពល៨០២ខ្ញុំ ។

ដានីៈ នៅកងពល៨០២វិញ?

ចំរើនៈ ចា៎! ៨០២មកនៅទន្លេល្ពៅហ្នឹង កងដឹកជញ្ជូន ។

ដានីៈ ទន្លេល្ពៅហ្នឹងយ៉ាងម៉េចគេបង្កើតកងពល៨០២ថ្មីទៀត ឬចាស់?

ចំរើនៈ តាំងពីខ្ញុំមិនទាន់មក តាំងពីឆ្នាំ៨០ គេបង្កើតឲ្យមានកងពល៨០១, ៨០២ ។ ខ្ញុំមកដល់ចូល នៅកងពល៨០២ ។

ដានីៈ យើងចូលទៅនៅ ឬគេចាត់ចែងឲ្យយើងចូលក្នុងហ្នឹង?

ចំរើនៈ គេចាត់ចែងឲ្យយើងចូលដឹកជញ្ជូនឲ្យកងពល៨០២ កងដឹកជញ្ជូន ។

ដានីៈ កងពល៨០២?

ចំរើនៈ ចា៎! ដឹកជញ្ជូនសំរាប់កងពល៨០២ ។

ដានីៈ ពីណានៅ៨០២ហ្នឹង?

ចំរើនៈ កាលហ្នឹងកងពល៨០១, ៨០២ គេរៀបចំមានមន្ទីរកងពល ខ្ញុំនៅក្នុង៨០២ហ្នឹងឯង កងដឹកជញ្ជូនឲ្យកងពល៨០២ ។

ដានីៈ កាលហ្នឹងពីណាធ្វើប្រធាន?

ចំរើនៈ ប្រធានកងពលមាន តាឆន ។

ដានីៈ តាឆន តែម្នាក់ទេ?

ចំរើនៈ មានក្រោមៗហ្នឹងដែរ គ្រាន់តែយើងស្គាល់វាមិនអស់ ព្រោះយើងនៅកងដឹកជញ្ជូន ស្គាល់ តែតាមវរសេនាធំ៨១, ៨២, ២៥៩ យើងស្គាល់ ។

ដានីៈ អីចឹងកងពល២០២វាមាន ។

ចំរើនៈ ៨០២ ។

ដានីៈ ៨០២មានវរសេនាធំ?

ចំរើនៈ ៨១, ៨២, ២៥៩ វាមាន៣ហ្នឹង ។

ដានីៈ មីងនៅក្នុងវរសេនាធំមួយណា?

ចំរើនៈ ខ្ញុំនៅ២៥៩ ។

ដានីៈ ពីណាគេប្រធានវរសេនាធំ?

ចំរើនៈ ប្រធានវរសេនាធំកាលហ្នឹង ២៥៩ កាលហ្នឹងមានតាពីន ។

ដានីៈ តាពីន គាត់ក្រុមប្រឹក្សាស្រុកដែរ?

ចំរើនៈ អត់ទេ គាត់នៅព្រះវិហារឥឡូវ ។

ដានីៈ ឈ្មោះ តាពិន?

ចំរើនៈ នោះតាពិន ក្រុមប្រឹក្សាស្រុក តាពីន គាត់ទៅនៅព្រះវិហារ ។

ដានីៈ នៅធ្វើកងទ័ព?

ចំរើនៈ ចា៎!

ដានីៈ ចុះ៨២?

ចំរើនៈ ឆ្នាំ៨២ក៏ខ្ញុំនៅហ្នឹងរហូតទល់ឆ្នាំ៨៤បានរត់ចេញពីហ្នឹង ។

ដានីៈ មីងនៅវរសេនាធំលេខ៨១, ៨២ ប្រធានវរសេនាធំគេឈ្មោះអីដែលទៅ?

ចំរើនៈ ៨២ តាឆន ។ កងពលកាលហ្នឹងតាសារឿន ប្រធានកងពល៨០២ ។ តាសារឿន យើង ។

ដានីៈ ០៥?

ចំរើនៈ ០៥ហ្នឹង ៨០២ ។

ដានីៈ ចុះ៨០១?

ចំរើនៈ ៨០១ហ្នឹងពីណាទេ ស្គាល់តែវរសេនាធំតាឃន វរសេនាធំ៨០១ មានតែខ្ញុំក្មេង ។

ដានីៈ មីងនៅក្នុងវរសេនាធំ?

ចំរើនៈ ២៥៩ ។

ដានីៈ នៅខាងជីកជញ្ជូន?

ចំរើនៈ ចា៎!

ដានីៈ នៅខាងទន្លេល្អៅមានប៉ុន្មានកងពលទៅ?

ចំរើនៈ ដូចតែមួយកងពល ។

ដានី៖ ហើយខាងហ្នឹងឃើញតែតាខៀវ ទេ?

ចំរើន៖ ចា៎! មានតែតាខៀវ ។

ដានី៖ ពីកន្លែង១០០១ពីត្រឹមណា ដល់ត្រឹមណាទៅ?

ចំរើន៖ ១០០១ មួយវង្វង់មុំ៣ ។

ដានី៖ តែមួយវង្វង់មុំ៣ហ្នឹងទេ?

ចំរើន៖ ចា៎! មុំ៣ ។

ដានី៖ មកខាងប្រុកផ្សេងទៀតអត់ទេ?

ចំរើន៖ អត់ទេ មកនេះ១០០៣ ខាងតាម៉ុក ។

ដានី៖ ចុះ១០០២?មាន១០០២ទេ? ព្រោះកន្លែង១០០១កន្លែងមុំ៣ ។

ចំរើន៖ ១០០២មិនដឹងនៅប្រុកណាទេ កាលហ្នឹងខ្ញុំដូចជាដឹងតែ១០០១, ១០០៣ ។ ១០០២ ដូចអត់មានលឺ អត់ដឹងប្រុកណា ។ យើងកាលនោះធម្មតាទេ យើងគ្រាន់តែកងដឹកជញ្ជូន យើងមិនសូវជាចាប់អារម្មណ៍ ។

ដានី៖ ចុះប្រុកខាងអានសេះអី?

ចំរើន៖ ប្រុកអានសេះក៏នៅក្នុងកងពលហ្នឹងដែរ ។

ដានី៖ កងពលណា?

ចំរើន៖ ១០០១ហ្នឹងឯង អានសេះ ដឹកជញ្ជូនពីទន្លេល្អៅហ្នឹងទៅអានសេះ ទៅភ្នំរូង ហ្នឹងគេវ៉ៃមក ដាំក្បាន្ត មកវាលជៀស គ្រាន់អានសេះទៅម្តងៗទេ ។

ដានី៖ អានសេះហ្នឹងក្នុង១០០១ទេ?

ចំរើន៖ ចា៎! ក្នុង១០០១ដដែល ។ ប្រុកចាប់ដៃ ១០០៣ ។

ដានី៖ ដល់ឆ្នាំណាបានមីងរៀបការ?

ចំរើន៖ ខ្ញុំរៀបការឆ្នាំ៨២ ។

ដានី៖ មកដល់លើ?

ចំរើន៖ ការហើយក៏នៅតែដឹកជញ្ជូនដែរ ។

ដានី៖ ពេលដែលឆ្នាំ៨២ ការនៅទន្លេល្អៅ?

ចំរើន៖ ចា៎! ការនៅទន្លេល្អៅ ។

ដានី៖ កាលហ្នឹងពូធ្វើអី?

ចំរើន៖ កងទ័ពដែរ ។

ដានី៖ កងទ័ពនៅក្នុងកងពលណា?

ចំរើនៈ នៅ២៥៩ ។

ដានីៈ ការហើយមីងក៏នៅតែដឹកជញ្ជូនដដែល?

ចំរើនៈ រហូតទាល់តែយើងមានកូន មានចៅទៅឈប់ ។

ដានីៈ តែពូ?

ចំរើនៈ ពូនៅតែកងទ័ពដដែល តែស្លាប់បាត់ហើយ ហ្នឹងគ្រួសារខ្ញុំមុន ។

ដានីៈ គាត់ស្លាប់តាំងពីអន្កាល់?

ចំរើនៈ ស្លាប់ឆ្នាំ៨៤ ។

ដានីៈ គាត់ឈ្មោះអីទៅ?

ចំរើនៈ អ៊ុន អេន ។ ខ្ញុំសំរាលកូនស្រីបាន៧ថ្ងៃ គាត់ស្លាប់ ជាន់មីន ។

ដានីៈ បានកូនប៉ុន្មានជាមួយគាត់?

ចំរើនៈ កូន២ បងគេ ប្រុស១ ស្រី១ ។

ដានីៈ មីងរៀបការទៀតឆ្នាំណាទៅ?

ចំរើនៈ ៨៦ហើយ យើងនៅតែឯងហើយរត់រាល់តែថ្ងៃវាពិបាក ណាកូនចៅ ណាអន្ករហូប គេសួរទៀតក៏យកទៅ ។

ដានីៈ អីចឹងមីងនៅទន្លេល្អោរហូតដល់ឆ្នាំប៉ែតប៉ុន្មាន?

ចំរើនៈ ៨៤ ។

ដានីៈ យ៉ាងម៉េចបានជាយើងចេញពីទន្លេល្អោ?

ចំរើនៈ កាលហ្នឹងកងទ័ពវៀតណាម កងទ័ពរដ្ឋាភិបាលវ៉ៃបុកចូលដល់ទន្លេល្អោ បានរត់ចេញពីហ្នឹងទៅដីថៃ ធ្លាក់មក១០០៣ មកនៅម្តុំយើងចងក ។

ដានីៈ អីចឹងកងទ័ពខាងវៀតណាម ខាងរដ្ឋាភិបាលគេវ៉ៃចូល យើងរត់ចូលដីថៃ?

ចំរើនៈ ចាំ!

ដានីៈ កាលហ្នឹងគ្នាច្រើនទេរត់ទៅ?

ចំរើនៈ ច្រើនមនុស្សរាប់កងពលហ្នឹង ។

ដានីៈ ទាំងប្រជាជនដែរ?

ចំរើនៈ ទាំងប្រជាជន ទាំងកងទ័ព ឡើងបាក់ទឹក បាក់ដីរត់ទៅដីថៃ ។

ដានីៈ ពីណាដឹកនាំរត់ទៅ?

ចំរើនៈ កាលហ្នឹងធម្មតាទេ ដល់ពេលគេវ៉ៃបែក តាខៀវ គាត់ទៅតាមរយៈផ្លូវថៃ យើងប្រជាជនតាមវរសេនាធំ, វរសេនាធំ តាមគ្នា យកតែរួចខ្លួន ។ គ្រាន់តែវាអត់រត់បែកគ្នា ទៅណា

ទៅហ្នឹងទាំងអស់គ្នា វេទនាណាស់ខ្ញុំនិយាយមិនអស់ បើយើងនិយាយការលំបាក ដល់និយាយឲ្យកូនស្ដាប់ កូនថាម៉ែឯងចេះតែថាទៅ គ្មានអ្នកណាលំបាកដល់ប៉ុណ្ណឹងទេ ។

ដានី: មីងអាចរៀបរាប់គិតមើល ព្រោះខ្ញុំសរសេរ ខ្ញុំត្រូវការចង់ដឹង ។

ចំរើន: បើនិយាយការលំបាក វាលំបាកតាំងពីយើងនៅព្រៃ តាំងពី៧៩យើងរត់ចូលព្រៃ តាំងពី៧៩មកយើងដាច់ហើយអត់មានអង្ករ រត់ទៅនៅព្រៃ ។ កាលដំបូងយើងចេះតែយកលាក់បានតាមព្រៃ ដល់រយៈ៤-៥ខែយើងហូបអស់កំលាំងច្រើន ដល់អីចឹងក៏ចែកតាមវរសេនាតូចៗ នៅដោយក្រុម ដើររកជីកក្ដួច ជីកដំឡូងហូបទៅ ។ ទៅព្រៃណាដែលមានព្រៃក្ដួចនិងមានទឹកស្នាក់នៅហ្នឹងហើយ នៅធ្វើក្ដួចហូបល្មមអស់ហើយដើររកទៀត រកកន្លែងណាមានក្ដួច មានទឹក នៅហ្នឹងទៀត ។ ខែវស្សាបេះស្លឹកថ្កុងធ្វើរោងសំរាក បើខែប្រាំងទៅដល់កន្លែងណាបោសដីដេកត្រង់ហ្នឹង ជីកក្ដួចហូប ។ ខ្ញុំថាមិនសមបានរស់ទេ ទោះបីយើងរត់រហូតក៏នៅតែកងទ័ពវៀតណាមតាមទាន់រហូត ។

ដានី: អីចឹង?

ចំរើន: សឹងតែថាមួយខែ៣០ថ្ងៃ ដើរទាំង៣០ថ្ងៃនៅតែទាន់ ។ យើងរត់កំលាំងធំអីចឹងយើងទៅតាមដែនទឹកន្លែងណាមានទឹក ហើយគេដើររកតាមដែនទីដែរ ទាន់រហូតវៃងាប់តាមផ្លូវរាប់មិនអស់ទេ និយាយទៅមួយអនុសេនាធំនៅសល់៣-៤នាក់ក៏មាន ។

ដានី: ស្លាប់ច្រើន អ្នកដែលរស់អាយុថ្ងៃ?

ចំរើន: បានខ្ញុំថាអាយុថ្ងៃណាស់អ្នកដែលនៅរស់ ។

ដានី: មីងអត់មានត្រូវរបួសអីទេ?

ចំរើន: ខ្ញុំអត់ទេ អីចឹងបានខ្ញុំថាខ្ញុំអាយុថ្ងៃដែរ ពេលកំពុងតែអង្គុយហូបក្ដួចអីចឹងទៅ វៃចំកន្លែងក្ដុងក្ដាំងៗអ្នកស្លាប់ក៏ស្លាប់ អ្នករបួសក៏របួស អ្នករត់រួចរត់ទៅ ។

ដានី: យើងអត់គិតទេ ឲ្យតែរួចខ្លួន?

ចំរើន: អត់គិតទេ ឲ្យតែរត់រួចខ្លួន ដូចអ្នកឈឺធម្មតាការរស់នៅក្នុងព្រៃនោះ ទី១អត់ថ្នាំសង្កូវ ទី២ហូបចុកអត់គ្រប់គ្រាន់ ខ្វះជីវជាតិ ខ្វះរាករូស ខ្វះគ្រុនចាញ់ អ្នកទៅរួចក៏ទៅ អ្នកទៅមិនរួចក៏នៅហ្នឹង ស្លាប់ច្រើនណាស់ ហើយកាលនោះនិយាយទៅកងទ័ពវៀតណាមក៏សាហាវដែរ ចាប់បានខ្វះចាប់ហែកដៃ ហែកជើង ដល់ឃើញអីចឹងចេះតែរត់ទៀតហើយ ។ ម្យ៉ាងស្រុកកំណើតក៏វានៅឆ្ងាយដូចខ្ញុំនិយាយទៅ យើងទៅស្រុកវិញមិនដឹងទៅផ្លូវណាដែររកមិនឃើញ អីចឹងចេះតែទៅតាមគេ តាមដំណើរទៅ គេទៅណាទៅហ្នឹងគេ ។ បើនិយាយថាស្នេហាជាតិក៏មិនស្នេហាជាតិដល់ប៉ុណ្ណោះដែរ តែវារកច្រកទៅមិនឃើញ ហើយធម្មតាសង្គ្រាមចិត្ត

សាស្ត្រហ្នឹងវាខ្លាំងណាស់ មិនដឹងគេនៅក្នុងគេរស់នៅស្រុកស្រួលអត់ទេ ធម្មតាតែរស់នៅកន្លែងណាច្រើនតែស្តាប់ការអប់រំរបស់ខាងហ្នឹងហើយ ឃោសនាថាចេះចុះ យួនធ្វើបាបធ្វើទុក្ខបុកម្នេញ យើងចេះតែខ្លាចទៅ ចេះតែរស់នៅនឹងគេឯង វេទនាហូបក្តួច ហូបដំឡូងជូនកាលមួយអនុសេនាធំសល់១០-១៥នាក់យ៉ាងច្រើន ឈឺក៏ឈឺ ត្រូវគ្រាប់ក៏ត្រូវ ។

ដានី: មីងពេលយើងឆ្លងទន្លេ យើងមានពេទ្យត្រឹមត្រូវទេ?

ចំរើន: ឆ្លងទន្លេមានពេទ្យណា យើងមានថ្នាំសង្កូវអីណា ឧទាហរណ៍ថារត់ៗឈឺពោះ ហើយក៏ដូចជាស្រួលដែរមិនមានអីទេកាលនោះ ថាឈឺពោះៗហ្នឹង កើតហ្នឹង កាត់ទងដ្ឋីងហើយបីកូនទៅទៀតហើយ អត់អីដែរ អីចឹងបានខ្ញុំឆ្ងល់មកដល់ឥឡូវយើងយកចិត្តទុកដាក់ណាស់ គ្រោះថ្នាក់ណាស់ បើកាលជំនាន់នោះគ្មានទេ មានតែដើមឫសឈើដាំហូប សំរាលហើយ ។

ដានី: កាលមីងមកដល់មុំ ទន្លេល្ពៅ យើងមានពេទ្យ?

ចំរើន: ហ្នឹងមានមន្ទីរពេទ្យ ថ្នាំសំបូរណាស់យើងមកនៅមុំ៣ ថ្នាំហូបចុកអត់ខ្វះដែរ រឿងហូបចុកគេជំនួយមិនដឹងមកពីខាងណា ហូបអត់ខ្វះទេមកដល់មុំ៣ គ្រាន់តែថាម្ហូបកំប៉ុង ធម្មតារបស់គេជំនួយ ។

ដានី: ហ្នឹងពេលមីងមានគ្រួសារ ពេលឆ្លងទន្លេនៅកន្លែងមុំ៣?

ចំរើន: ហ្នឹងអត់អីទេ ។

ដានី: មានមន្ទីរពេទ្យ?

ចំរើន: គេមានមន្ទីរពេទ្យដែរ តែយើងមិនដែលទៅសំរាលនៅពេទ្យទេកាលនោះ នៅតែផ្ទះតាមឆ្មបបុរាណហ្នឹង អត់អីទេ កាលហ្នឹងហូបចុកគ្រប់គ្រាន់ ។

ដានី: កាលហ្នឹងប្រធានមន្ទីរពេទ្យគេពីណាគេ?

ចំរើន: កាលខ្ញុំនៅនេះមានតាឡូន ឥឡូវគាត់ទៅ ។ មន្ទីរពេទ្យប្រធានមន្ទីរពេទ្យហ្នឹងឈ្មោះឡូន ។

ដានី: គាត់ទៅណាវិញទៅឥឡូវ?

ចំរើន: ថាទៅលិចៗមិនដឹងទៅខាងណាទេ នៅខាង១០០៣ហ្នឹងឯង ទៅខាងតាកាលនោះ ។ កាលហ្នឹងគាត់នៅជាមួយតាសុន សេន (នៅជាមួយតាខៀវ) ដល់ក្រោយមកគេដកគាត់ទៅកន្លែងខាងលិច ប្រហែលកន្លែងតាម៉ុក, តាប៉ុល ពតឯង ព្រោះអីតែនេះមានបញ្ហាអីគេដកទៅហ្នឹងហើយ ។

ដានី: ដកទៅ?

ចំរើន: ដកទៅនៅកន្លែងមេធំ ។

ដានី: លិច?

ចំរើនៈ	គេថាលិចៗ ដីឥណាទេ គេថាលិច ។

ដានីៈ	អាចទៅខាងកំរៀង, ភ្នំព្រឹក?

ចំរើនៈ	ប្រហែលជាទៅហ្នឹង ខាងបៃលិន ។ តែបរិបូរណ៍ណាស់ពេទ្យជំនាន់ហ្នឹង ពេទ្យនៅមុំ៣ ថ្នាំចាក់ក៏មិនខ្វះ ។

ដានីៈ	ដូចគ្រួសារ ប្រជាជននៅខាងក្រោយ នៅខាងទន្លេល្អៅពីណាអ្នកគ្រប់គ្រង?

ចំរើនៈ	ប្រជាជនកាលហ្នឹងមានតាអាន ។

ដានីៈ	តាអាន តែម្នាក់ទេ?

ចំរើនៈ	ចា៎! មានគេហៅភូមិតាអានៗ ហ្នឹងសុទ្ធតែប្រជាជន តាមភូមិដែលតាមជាយដែនរត់ឡើងទៅ ។

ដានីៈ	កាលហ្នឹងមីងអត់នៅក្នុងភូមិទេ នៅក្នុងមន្ទីរកងពល?

ចំរើនៈ	អត់ទេ ខ្ញុំនៅកងទ័ពនៅឡើយ ។

ដានីៈ	មានភូមិតាអាន មួយតែភូមិហ្នឹងធំ?

ចំរើនៈ	ហ្នឹងហើយ និយាយទៅឲ្យតែប្រជាជនគេដាក់ទៅហ្នឹងឯង ។

ដានីៈ	ដល់ពេលរត់ទៅឆ្នាំ៨៤ ពេលដែលទាហានខាងវៀតណាម ខាងរដ្ឋាភិបាលគេចូលទៅលុកលុយយើងរត់ទៅថៃ យើងទៅនៅថៃបានយូរទេ?

ចំរើនៈ	ទៅនៅតាមព្រំដែន វាមិនឲ្យចូលទៅដីវាដែរ យើងទៅនៅតាមព្រំដែន ទំរាំគេដោះស្រាយបានសំរួល ឬគេរកទីតាំងណាបានមាំមួនទៅគេជំរុញទៅនៅហ្នឹង ហើយកងទ័ពចុះមកទៀតមក ។

ដានីៈ	មីងទៅនៅដីថៃបានរយៈពេលប៉ុន្មានទៅ?

ចំរើនៈ	ខ្ញុំអត់ដែលចូលទៅដល់ស្រុកថៃទេនៅតាមព្រំដែន ។

ដានីៈ	តាមព្រំដែនហ្នឹងបានយូរទេបានចេញមកវិញ?

ចំរើនៈ	នៅឆ្នាំតាំងពី៨៤ មក៩៣យើងជំនាន់អ៊ុនតាក់ ហ្នឹងខ្ញុំនៅព្រំដែនថៃហ្នឹងឯង ។

ដានីៈ	តែយើងរត់ចេញពីទន្លេល្អៅមក?

ចំរើនៈ	ចេញពីទន្លេល្អៅមកហ្នឹង ។

ដានីៈ	មកនៅណាទៅ?

ចំរើនៈ	ចេញពីទន្លេល្អៅមកនៅជាំពិការ នៅព្រំដែនថៃដែរ ។

ដានីៈ	គេហៅអីគេ?

ចំរើនៈ	ដាំពិការ គេហៅស៊ីងចាន់ៗ ធម្មតាយើងទៅនៅត្រង់ណាយើងហៅឈ្មោះហ្នឹង នៅម្តុំចងក អូរត្រាវ ខ្លះគេចូលជំរំអូរត្រាវ ខ្លះគេអត់ទៅ ដូចពួកខ្ញុំអត់ចូលជំរំទេ អីចឹងនៅនឹងភូមិចងក នៅនឹងព្រំដែន ជិតគ្នា ។

ដានីៈ	ហ្នឹងជិតស៊ីងចាន់អត់ទេ?

ចំរើនៈ	ចា៎! ជិតគ្នា ស៊ីងចាន់ជិតគ្នា យើងចង់ទៅផ្សារយើងទៅជំរំអូរត្រាវ ។

ដានីៈ	បើទៅជំរំអូរត្រាវបានមានផ្សារ?

ចំរើនៈ	បានមានផ្សារ នៅខ្មែរក្រហម ដីតាមភូមិអត់មានទេ នៅអូរត្រាវហ្នឹងបានដល់ឆ្នាំ៩៣ យើងអ៊ុនតាក់គេបោះឆ្នោត អ៊ុនតាក់ចូលហ្នឹង បងខ្ញុំគាត់នៅជំរំអូរត្រាវ បងស្រីដែលរត់ជាមួយគ្នា គាត់នៅជំរំអូរត្រាវ ដល់ពេលជនាន់អ៊ុនតាក់គេដឹកជនភៀសខ្លួនអ្នកចង់ទៅស្រុកកំណើតអីគាត់ទៅតាមរយៈហ្នឹងបានដល់ស្រុក ។ ហើយខ្ញុំគ្រួសារខ្ញុំអត់ទៅ គាត់ថាមិនដឹងស្រុក ដឹងទៅរកអី បើដីកេរ្តិ៍អាករក៏គ្មាន បាតដៃទទេ ក៏ចេះតែនៅទៅ នឹកឃើញថាវាស្រួលបួលដែរកាលនោះ ចេះតែនៅហ្នឹងទៅ ។

ដានីៈ	បងស្រីមីងគាត់ទៅដល់ស្រុក?

ចំរើនៈ	ចា៎! គាត់ទៅដល់ស្រុក ។

ដានីៈ	ទៅដល់ខាងស្រុកកំណើតមីង?

ចំរើនៈ	ចា៎! កំពង់ស្ពឺហ្នឹងឯង តាំងពី៩៣រហូតដល់៩៨ដែលខ្ញុំផ្លាច់ខ្លួននេះ បានខ្ញុំទៅបានយកមកវិញ ទៅនោះវាអត់មានដី ។

ដានីៈ	អត់មានដី?

ចំរើនៈ	ចា៎! អត់មានដី នឹកឃើញសំរាប់គាត់តែម្នាក់គាត់ចេះតែនៅបានហើយ ព្រោះកេរ្តិ៍អាករតិចតួចកេរ្តិ៍ពីឪពុកម្តាយមក ចុះដល់កូនគាត់ទៀត ចៅគាត់ទៀតបានអី អីចឹងខ្ញុំយកមកនេះបាន២គ្រួសារទៀត មកនៅបាន៣គ្រួសារទាំងខ្ញុំ ។

ដានីៈ	អីចឹងគាត់នៅស្រុកក៏មកជាមួយដែរ?

ចំរើនៈ	មកជាមួយដែរ ។

ដានីៈ	មីងមានប្រសាសន៍មុញមីងអត់នៅក្នុងជំរំទេ តែបងស្រីនៅក្នុងជំរំ ។ ម៉េចបានមីងអត់ចង់នៅក្នុងជំរំអូរត្រាវ?

ចំរើនៈ	កាលនោះនៅជំរំ យើងនៅក្រៅជំរំមែន តែយើងបានទៅដាក់ឈ្មោះបើកអង្ករនៅក្នុងជំរំដែរ តែយើងអត់ទៅនៅក្នុងហ្នឹងទេ ប្តីយើងនៅកងទ័ព ។ បើអ្នកជំរំគេអត់ធ្វើកងទ័ពទេ ។

ដានីៈ	គ្រួសារមីងក្រោយគាត់ធ្វើកងទ័ពដែរ?

ចំរើនៈ ចា៎!

ដានីៈ កងទ័ពនៅណាទៅ?

ចំរើនៈ នៅ៨០២ហ្នឹងដែរ ។

ដានីៈ អីចឹងគាត់នៅកងទ័ព មីងនៅជិតគាត់?

ចំរើនៈ ចា៎! នៅជាមួយគ្នា ហើយគ្រួសារខ្ញុំពិការគេឲ្យនៅក្រោយ ពេលយើងមានអាសន្នបានជួយយកគ្មារត់ យកប្រពន្ធទៅដាក់ហើយមកការពារវិញ ។ នៅតំបន់នេះយើងបានឆ្នាំ៩៣មកនៅមួយសារហើយ កាលនោះក្រោយពី៩៣ទៅបោះឆ្នោតរួច នៅវៃគ្នាមួយសារទៀតខ្ញុំនៅហ្នឹងឯង ។ និយាយពីយន្តហោះនាំគ្នានៅត្រង់សេហើយ កាលហ្នឹងយន្តហោះរដ្ឋាភិបាលមកទម្លាក់នៅហ្នឹងឯង ។

ដានីៈ មកទម្លាក់ដែរ?

ចំរើនៈ មកទម្លាក់ហ្នឹងឯង រត់រហូត ។ និយាយទៅចាប់តាំងពីខែ១០-១១-១២ទៅហ្នឹងដឹងតែត្រៀមខ្លួនរត់ហើយ ចាប់ពីខែ១០ត្រៀមខ្លួនរត់ ដោយសារអីពី១០វាអស់ទឹកភ្លៀងរថក្រោះមករួច ថ្មើរជើងក៏មកដល់ហ្នឹងដែរ ចូលដល់ខែ៤-៥ ភ្លៀងធ្លាក់ហ្នឹងរថក្រោះមកអត់រួច ថ្មើរជើងមកអត់រួចដែរ យើងមកប្រកបធ្វើស្រែ ចំការនៅអីចឹងដែរ បានស្រូវហើយរត់ចោលទៅ ហ្នឹងកាលមុនផ្ដាច់ខ្លួន ។ ខ្ញុំថាវេទនាណាស់វាមិនសមបានរស់ប៉ុណ្ណេះវាដូចយល់សប្តិ ។

ដានីៈ មីងពេលកងទ័ពវៀតណាមគេដកទៅ ឆ្នាំ៨៩-៩០ កាលហ្នឹងយើងមានចុះពីព្រំដែនមកនៅហើយឬមិនទាន់ទេ? មុនអ៊ុនតាក់ចូលឆ្នាំ៩៣?

ចំរើនៈ ចុះមកហើយ ចុះមកនៅអន្លង់វែង-ត្រពាំងប្រាសាទហ្នឹង ហ្នឹងចុះពីហ្នឹងមក ចុះពីព្រំដែនមក

ដានីៈ ចុះព្រំដែនឆ្នាំណាដែលមីងចុះមក?

ចំរើនៈ ៩៣ ។

ដានីៈ ឆ្នាំ៩៣?

ចំរើនៈ ចា៎! ៩៣ចុះពីព្រំដែនថៃមកហើយ មកនៅអន្លង់វែង-ត្រពាំងប្រាសាទហ្នឹងឯង ទើបមកនៅ៩៣ហ្នឹងទេ ។

ដានីៈ ដំបូងបំផុតមីងនៅណាទៅ?

ចំរើនៈ នៅជិតអូរគ្រាវ នៅចងកងហ្នឹង ។

ដានីៈ ឆ្នាំ៩៣ហ្នឹង?

ចំរើនៈ ចាំ! អាគេកំពុងតែចរចារគ្នាមានអ៊ុនតាក់ មុនគេចរចារនៅនោះទេ ដល់ពេលគេចរចារហើយមានអ៊ុនតាក់ចុះមកនៅនេះ ។

ដានីៈ ចុះមកនៅណា?

ចំរើនៈ ចុះមកនៅហ្នឹងឯង ត្រពាំងប្រាសាទ ។

ដានីៈ ឆ្នាំណាដែលមីងចុះមកនៅត្រពាំងប្រាសាទ?

ចំរើនៈ ឆ្នាំ៩៣ ។ ព្រៃចូលមិនចុះទេតាមនេះ សុទ្ធតែព្រៃណែន តាម៉ុកដឹកយកមកដាក់តាមផ្លូវឡានហ្នឹងឯង ហើយកាលហ្នឹងឡានធ្វើផ្លូវហ្នឹងគគ្រឹក ហើយយកប្រជាពលរដ្ឋមកដាក់តាមផ្លូវ ហើយឡានថៃដឹកឈើ ហើយឡានធ្វើផ្លូវ មួយយប់ៗថាសឹងមិនបានដេកទេកាលនោះចំណូលរបស់តាម៉ុក គឺព្រៃឈើហ្នឹងឯង ដឹកឈើ បានជំនួយគេឲ្យឡាន អាត្រាក់ធ្វើផ្លូវផ្លូវហ្នឹងតាំងពីជំនាន់តាម៉ុក ធ្វើហ្នឹង ។

ដានីៈ ខាងហ្នឹងមានមីន?

ចំរើនៈ មីនមាន ដោយសារពេលកងកំលាំងឡើងមកយើងដាក់មីនការពារ រុញប្រជាពលរដ្ឋទៅក្រោយតាមអស់ហ្នឹងយើងដាក់មីន ដល់ហើយបានដោះបានមកនៅធ្វើស្រែ ចំការ ។

ដានីៈ ឥឡូវអស់ហើយ?

ចំរើនៈ អត់មានទេតាមនេះ ។ ព្រោះអត់មានកងទ័ពវៀតណាមដាក់ទេ មានតែខ្មែរក្រហមដាក់ការពារតំបន់ខ្លួនឯងហ្នឹង អីចឹងដឹងក៏គេដោះទៅ ។

ដានីៈ ដល់ពេលមកឆ្នាំ៩៣មានរត់ចេញពីផ្ទះទៀតអត់?

ចំរើនៈ រត់ ។

ដានីៈ រត់ទៀត?

ចំរើនៈ ក្រោយពេលបោះឆ្នោតហើយយើងវៃគ្នាមួយសារទៀត រត់ដូចខ្ញុំនិយាយម៉ិញអីចឹង ខែ ១០-១២រត់ ដល់ខែ៥បកមកវិញហើយ ។

ដានីៈ ម៉េចអីចឹង?

ចំរើនៈ តែខែ១០-១១អស់ទឹកភ្លៀងរថក្រោះមករួច ថ្មើរជើងទាហានក៏មកដល់ហ្នឹងដែរ ដល់អីចឹងជម្លៀសប្រជាជនរត់ទៅក្រោយ កងទ័ពនៅការពារភូមិ ដល់ខែ៤-៥ទឹកភ្លៀងមកបកមកវិញ ហ្នឹងទាហានក៏អត់ហ៊ានមកដែរ រថក្រោះមកអត់រួចវាទឹក ។ ជាប្រចាំរហូតដល់ឆ្នាំ៩៨ផ្តាច់ខ្លួនហ្នឹងឯងបានឈប់រត់ រត់រាល់ឆ្នាំ ។

ដានីៈ មីងទាក់ទងបញ្ហាក្រោយមកមានបែកបាក់កំលាំង ដូចកំលាំងខាងតាម៉ុក, ខាងប៉ុល ពត?

ចំរើនៈ ហ្នឹងមានបែកកំលាំងកាលហ្នឹង ។

ដានីៈ មីងមានដឹងរឿងហ្នឹងដែរ? យ៉ាងម៉េចបានទៅជាបែកបាក់?

ចំរើនៈ ខ្ញុំអត់សូវដឹងដែររឿងផ្ទៃក្នុងកាលនោះ ព្រោះខ្ញុំនៅជាប្រជាពលរដ្ឋដែរ យើងអត់ដឹងការងារផ្ទៃក្នុងគេទេ ការងាររបស់មេៗ ហើយប៉ែកខាងលិច ខាងអន្លង់វែង ខាងតាម៉ុក ខាងត្រពាំងប្រាសាទហ្នឹង០៥ កងពល៨០១ ដល់ពេលខ្ញុំដឹងសភាពការណ៍វាមិនស្រួលផ្ទៃក្នុងៗ កាលនោះខ្ញុំនៅដឹកនាំភូមិ ខ្ញុំធ្វើមេភូមិ ដល់សភាពការណ៍អីចឹងទៅមានការផ្តាច់ខ្លួននៅទំនប់ផ្តាច់ ប្អូនខ្ញុំគេផ្តាច់ខ្លួនទៅជាំក្សាន្តៗ តាម៉ុក គាត់ចាប់មេៗយើងខាងនេះ មេៗខាង៨០២ គាត់ចាប់០៥, តាជុ យើងដឹងថាសភាពការណ៍វាអត់ស្រួលទេ ព្រោះកាលមុនយើងរត់តែខាងរដ្ឋាភិបាលវ៉ៃ តែឥឡូវនេះផ្ទៃក្នុងសងខាង ដូចបែកបក្សគ្នា៨០១, ៨០២អីចឹងៗ ឃើញសភាពការណ៍ហ្នឹងវាអត់ស្រួល ក៏មេខ្ញុំរត់ តាជុគាត់រត់ទៅសារភាពនៅព្រះវិហារ ដល់ក្រោយមកទៀតខាងកងទ័ព តាលាវ គាត់ទៅសារភាពនៅព្រះវិហារៗ ខ្ញុំគិតឃើញថាសភាពការណ៍នេះមិននៅយូរទេ ព្រោះបែកបាក់ផ្ទៃក្នុងដឹងតែរលាយហើយ បើគាត់ទាំង២នៅសាមគ្គីគ្នាដូចគ្នា មិនងាយបែកទេអន្លង់វែងនេះៗ ដោយសារអីចឹងតាម៉ុក ហើយនិង០៥ ហើយរឿងសុន សេន ស្លាប់ ហ្នឹងជារឿងផ្ទៃក្នុងយើងក៏មិនដឹងដែរ ចេះតែចោទទៅម្ខាងៗ ។ ០៥ថាតាម៉ុក សម្លាប់ ហើយតាម៉ុក ថា០៥សម្លាប់ ហើយយើងប្រជាពលរដ្ឋយើងអត់ដឹងទេៗ

ដានីៈ រឿងតាសុន សេន ស្លាប់ហ្នឹងខាងតា០៥ ថាខាងតាម៉ុក អ្នកសម្លាប់?

ចំរើនៈ ចា៎! ហើយតាម៉ុក ថា០៥អ្នកសម្លាប់ អីចឹងចោទគ្នាទៅវិញទៅមកៗ

ដានីៈ ម៉េចបានមីងដឹង តា០៥ អ្នកនិយាយ ឬយ៉ាងម៉េច?

ចំរើនៈ ចា៎! កាលនោះពេលដែលមានបញ្ហាអីចឹងកើតឡើង តែងតែកោះហៅប្រជុំហើយគេនិយាយពីសភាពការណ៍ចេះៗ ៗ

ដានីៈ មីងផ្ទាល់ពេលគេហៅទៅប្រជុំ តា០៥ គាត់និយាយផ្ទាល់តែម្តង ថាតាសុន សេន ហ្នឹងស្លាប់ដោយសារតាម៉ុក អ្នកសម្លាប់?

ចំរើនៈ អត់និយាយផ្ទាល់ទេ គ្រាន់តែថាសភាពការណ៍ហ្នឹងយើងឃើញវារំដើបរំជួល យើងប្រជាពលរដ្ឋក៏អាចវិភាគបានដែរ ចុះវានៅក្នុងតំបន់ៗ តាសុន សេន កាលពីមុនគាត់នៅ ១០០១ គាត់គ្រប់គ្រងខាង១០០១ ដល់គាត់មក១០០៣ គាត់មកនៅនេះគាត់ស្លាប់ អីចឹងយើងគិតថាភាគីរបស់គាត់ហ្នឹងឯងទំនាស់គ្នាហើយ ៗ ០៥ គាត់កូនចៅរបស់សុន សេន អីចឹងបានយើងវិភាគថា និយាយទៅប៉ែកខាងត្រពាំងប្រាសាទថាតាម៉ុក សម្លាប់តាសុន សេនៗ ហើយគេខាងអន្លង់វែងថា០៥ ជាអ្នកសម្លាប់ តែការពិតក៏យើងអត់ទាន់ដឹង

ថាពីណាដែរ រហូតដល់ចាប់០៥, ០៦ អស់ទៅទៀត អីចឹងបានកូនចៅអស់មានជំនឿ អស់ទុកចិត្តផ្ដាច់ខ្លួន ប៉ែកខាងនេះ ។

ដានី: អត់មានជំនឿ អស់ទុកចិត្តខាងតាម៉ុក ទេ?

ចំរើន: អត់ទុកចិត្តទេ ពួកខ្ញុំសូម្បីតែខ្ញុំនៅនេះជាមួយយូរហើយក៏ខ្ញុំអត់ទុកចិត្តដែរ ពេលដែលផ្ដាច់ខ្លួនហើយ ខ្ញុំដឹងថាសភាពការណ៍ហ្នឹងវាបត់ហើយ គាត់ជម្លៀសប្រជាពលរដ្ឋមកនៅនេះ កាលមុននៅនោះទេ នៅខាងកើតអន្លង់វែង ។

ដានី: នៅខាងកើតអន្លង់វែងគេហៅអីគេ?

ចំរើន: កាលហ្នឹងគេហៅ៨០២ ខាងកើតអន្លង់វែង កង៨០២នៅហ្នឹងឯង ដល់អីចឹងគាត់ជម្លៀស គាត់ឲ្យប្រជាពលរដ្ឋមកនៅនេះ ។

ដានី: ឆ្នាំណាដែលគេជម្លៀស?

ចំរើន: ឆ្នាំ៩៨ហ្នឹងឯង ។

ដានី: ពីណាឲ្យជម្លៀស?

ចំរើន: តាម៉ុក ។

ដានី: តាម៉ុក ឲ្យជម្លៀសមកនៅនេះវិញ?

ចំរើន: ចា៎! គាត់ឲ្យជម្លៀសមកនៅនេះវិញ ហើយគ្នាអ្នកមកហ្នឹងក៏គ្នាអត់មានគោលបំណងនៅជាមួយតាម៉ុក ដែរ ។ ដូចថាមកនៅដាច់ស្រយ៉ាលអីចឹងក្រែងលោកងទ័ពរាជរដ្ឋាភិបាលបានមកផ្ដាច់ទៅ តែការពិតអត់បានអីចឹងវិញ គេមកនេះលាន់ខ្ញុំអត់មកទេ ខ្ញុំនឹកឃើញថាម៉េចៗខ្ញុំទៅខាងព្រះវិហារ ដល់ពេលមកនេះមានអីគ្រាន់តែសភាពការណ៍ប្រែប្រួល តាម៉ុកឲ្យឡានដឹកឡើងភ្នំអស់រលីងអ្នកមកនេះ គ្នាអត់បានផ្ដាច់ខ្លួនទេ តាម៉ុក ដឹកឡើងភ្នំអស់ ពួកខ្ញុំនៅនោះហ្នឹង ខ្ញុំកាត់ទៅបេះទៅទំនប់ដាច់ចូលព្រះវិហារទៅបានផ្ដាច់ខ្លួន ហើយគ្នាអ្នកចង់ផ្ដាច់ហ្នឹងទៅជាដឹកឡើងភ្នំទៅនៅដីថៃអស់រលីង ។

ដានី: តាម៉ុក ឲ្យឡានមកដឹក?

ចំរើន: យកឡានមកដឹកទាំងយប់ ទៅព្រួសៗអស់ ។

ដានី: ទៅហ្នឹងគេហៅអី? ជំរំអី?

ចំរើន: ទៅនៅស្អីគេជំរំគេក្រោយផ្ដាច់ខ្លួននេះ ។ នៅចាប់ពីជាំទៅនោះ កាលហ្នឹងជាំ នៅដីយើងខ្មែរក្រហម ។ ដល់គេបានប៉ុន្មានយូរដែរ៤-៥ខែទៅបានចុះមកវិញ ត្រូវរ៉ូវគ្នា ពួកខ្ញុំផ្ដាច់ខ្លួនទៅនៅទំនប់ដាច់ បានឯកឧត្ដមទា បាញ់ គាត់មកចុះយន្តហោះ បានផ្ដាច់ហើយនៅតែខ្លាចកងទ័ពខ្មែរក្រហមទៀត គ្នាឯងហ្នឹង ដេកអត់លក់ទេមួយយប់ៗ ។

ដានី៖ ខ្លាចគ្នាឯងវិញ?

ចំរើន៖ ចា៎! ខ្លាចគ្នាឯងមកលួចវៃទៀត ។

ដានី៖ កាលមុនយើងនៅជាមួយគ្នា?

ចំរើន៖ ចា៎! នៅជាមួយគ្នា អីចឹងបានថាមនុស្សកុំថាតោះបីរស់នៅរាប់ឆ្នាំ បែកគ្នាតែកន្លះខែ ឬ១ ខែមិនដឹងសតិអារម្មណ៍គេយ៉ាងម៉េច ។

ដានី៖ គិតអីចឹងវិញ?

ចំរើន៖ ត្រឹមទំនប់ថ្មីទៅទំនប់ដាច់ ដេកអត់លក់ទេតាមផ្លូវ ខ្លាចគេកាត់វៃ ។ កាត់វៃមែន ដូចថា យើងទៅនៅទំនប់ដាច់ហើយយើងមកយកស្រូវអង្ករនេះ នៅកងទ័ពខ្មែរក្រហមកាត់វៃទៀត កាលហ្នឹង ។

ដានី៖ ចុះរឿងសម្លាប់តាសុន សេន ដល់ពេលនេះចេះតែឆ្លើយដាក់គ្នា?

ចំរើន៖ ចា៎! ចេះតែឆ្លើយដាក់គ្នា ។

ដានី៖ ដល់ប្រជាជនខាងនោះទៅគេប្រាប់ថា០៥ អ្នកសម្លាប់ ដល់ខាងនេះគិតថាតាម៉ុកអ្នកសម្លាប់ ។ ដល់ក្រោយមកគេចាប់ ដូចថាក្បត់គ្នា តាម៉ុក ចោទថាប៉ុល ពត ក្បត់, ប៉ុល ពត ថា តាម៉ុក ក្បត់ ដល់តាម៉ុកគាត់ឈ្នះទៅគាត់ចាប់តាប៉ុល ពត ហើយគេកាត់ទោស ។ ខាងយើងហ្នឹងមានអារម្មណ៍យ៉ាងម៉េច ពេញចិត្តគាត់ធ្វើអីចឹងដែរ ឬមិនទេ? ឬគិតថាវា យ៉ាងម៉េច ឬមានល្បិចអី ឬមានបញ្ហាអីកើតឡើង?

ចំរើន៖ ដូចមិនមានល្បិចអីទេ និយាយទៅតាម៉ុក គាត់ល្បិចរបស់គាត់ដែរហ្នឹង គាត់ធ្វើបាបពួកខ្ញុំ ខាងនេះ គាត់ធ្វើបាបខាង០៥នេះឯង ។ និយាយទៅកម្មាភិបាលខាង០៥គាត់ចាប់យកទៅ ដាក់ពន្ធនាគាកន្លែងគាត់ហ្នឹងឯង អីចឹងយើងវាអស់ការទុកចិត្ត សូម្បីតែតាម៉ុក ស្លាប់ កូន តាម៉ុក យកប្រូក្រាមឲ្យទៅធ្វើបុណ្យ អត់មានអ្នកណាទៅ ។

ដានី៖ អត់ទៅទេ?

ចំរើន៖ អត់ទៅ ។

ដានី៖ កូនតាម៉ុក គាត់យកប្រូក្រាមមកដែរ?

ចំរើន៖ ចា៎! ហ្នឹងហើយ យកមកអញ្ជើញអ្នកស្គាល់ៗឲ្យទៅចូលរួមបុណ្យ អត់មានអ្នកណាទៅទេ ខាងនេះ ថាទីងណាធ្វើបាបពួកខ្ញុំកាលមុន និយាយទៅគ្នាអ្នកផ្ដាច់ខ្លួនរត់មកតាមនេះ យើងនៅខាងកើតអន្លង់វែងហ្នឹង ហើយរត់មកខាងនេះគេកាត់មិនដឹងជាប៉ុន្មានកាត់ទេ ទំរាំ គ្នារត់រួចទៅព្រះវិហារ កាលនោះ យូរៗទៅបែកបាក់គ្នាឯងខ្លាចដាងទាហានមកពីក្នុងទៀត បានថាវាកំសត់កំរណាស់ ។

ដានី: កាលគេកាត់ទោសប៉ុល ពត ខាងមីងដឹងទេ?

ចំរើន: ដឹងដែរ បានស្តាប់តាមវិទ្យុ មើលទូរទស្សន៍។

ដានី: អត់បានទៅផ្ទាល់?

ចំរើន: អត់ទេ។

ដានី: គេអត់ហៅទៅទេ?

ចំរើន: អត់ទេ។ កាលនោះរឿងមេៗគេធ្វើអី គេធ្វើតែគ្នាគេ មិនឲ្យយើងដឹង។

ដានី: ចុះពេលតាម៉ុក គាត់ចាប់០៥, ០៦ ហើយនិងមេៗមួយចំនួនយកទៅសម្លាប់ ខាងយើងដឹងអត់?

ចំរើន: ដឹងហើយ លែងទុកចិត្តហើយ លែងទុកចិត្តតាម៉ុកហើយចាប់ពីហ្នឹងមក។

ដានី: ដឹងថ្ងៃគេយកទៅសម្លាប់ស្លាប់បាត់ទៅ គេមានមកផ្សព្វផ្សាយ មកប្រាប់ដែរអត់?

ចំរើន: អត់មាននិយាយណា៎ សភាពការណ៍បត់ទៅ យើងផ្តាច់ខ្លួនទៅហ្នឹង គ្រាន់តែគេសម្លាប់០៥, ០៦ហើយ រដ្ឋាភិបាលអ្នកដែលទៅសារភាពនាំកំលាំងមក នាំកំលាំងរដ្ឋាភិបាលមកផ្តាច់ខ្លួនទៅ ពួកតាម៉ុក ចេះតែរត់ទៅនោះ ពួកខ្ញុំផ្តាច់ខ្លួន។

ដានី: សម្លាប់ហើយចាប់ផ្តើមសភាពការណ៍ជ្រួលច្របល់។

ចំរើន: ចា៎! ជ្រួលច្របល់។

ដានី: តាម៉ុក រត់?

ចំរើន: បើសិនណាយើងក្រនាំកំលាំងរដ្ឋាភិបាលមក គេធ្វើបាបអ្នកកូន ប្រពន្ធនៅនេះទៀត ដូចថាប្តីៗទៅសារភាព កងទ័ពនោះទៅសារភាព គេចាប់កូន ចាប់ប្រពន្ធយកទៅដាក់អន្លង់វែង។

ដានី: ចាប់ទៅច្រើនដែរ?

ចំរើន: គេចាប់ ចាប់ទាំងឡានៗ គេថាប្តីក្បត់។

ដានី: ប្រពន្ធ កូន ភ័យដែរ?

ចំរើន: ភ័យក៏ភ័យ ហើយម្យ៉ាងយើងមិនគិតថាអីចឹងទេ ខ្លាចគេសម្លាប់អស់ទាំងពូជៗទៀត។

ដានី: មីងទៅដែលអត់?

ចំរើន: ខ្ញុំអត់ទេ ប្អូនខ្ញុំ ប្អូនជីដូនមួយខ្ញុំគេផ្តាច់ខ្លួនទៅ ផ្តាច់ខាងព្រះវិហារ ខ្ញុំឃើញប្អូនថ្ងៃហ្នឹងលំបាក ខ្ញុំឲ្យកូនខ្ញុំទៅនៅជាមួយមើលគោ ៣ខែ ដល់ពេលនេះគេដឹកប្រពន្ធៗហ្នឹងទៀត គេជម្លៀសប្រពន្ធៗទៅអន្លង់វែងដោយទាំងកូនខ្ញុំទៅទៀត ដល់អីចឹងទៅកាលនោះមេៗនៅទាក់ទងបានខ្ញុំគិតថា បើសិនណាជាយូរក៏វេទនា មិនស្រួលគេយកកូនប្រពន្ធទៅសម្លាប់ចោលអស់មិនដឹង។

ដានី: កាលហ្នឹងឲ្យតែយើងមានរឿងអីគេប្រុនតែសម្លាប់?

ចំរើន: ចា៎! វាគ្មានតុលាការណាកាត់ក្តីៗ

ដានី: អត់ទុកអប់រំ កែប្រែទេ ដឹងតែខុស ដឹងតែសម្លាប់?

ចំរើន: យើងមិនដឹង និយាយទៅមិនមែនច្បាប់ហ្នឹងមកពីប៉ុល ពត អ្នករៀបចំច្បាប់ហ្នឹងមិនមែនទេ តែនៅខាងក្រោមៗមានគំនុំគំគួនគ្នាតិចតួចហ្នឹងដូចជាមានសិទ្ធិវ៉ៃមនុស្សចោល តែខាងលើអត់ដឹងទេ គាត់មិនដឹងទេ ប៉ុល ពតៗ ខ្ញុំរស់នៅជាមួយគាត់មិនដែលឃើញគាត់បញ្ជាវ៉ៃអានេះចោល អានោះចោល អត់ដែលទេៗ

ដានី: មីងធ្លាប់រស់នៅជាមួយគាត់ដែរ?

ចំរើន: ទេ យើងនៅក្រោមការគ្រប់គ្រងរបស់គាត់ តែវាមិនដែលឃើញមានបទបញ្ជាពីគាត់មកចេះៗ បើតាមយើងឃើញជាក់ស្តែង ដែលយើងរស់នៅជាមួយ សូម្បីតែវរសេនាតូចរស់នៅជាមួយស្អប់អ្នកណាមួយអីចឹងលួចយកគ្នាទៅវ៉ៃចោលបាត់ទៅ វាអីចឹងឯងៗ

ដានី: តាំងពីមីងមកនៅនេះ ឬតាំងពីនៅមណ្ឌលគិរី?

ចំរើន: តាំងពីយើងនៅវ៉ៃ យើងចេញពីមណ្ឌលគិរី ចេញ៧៩យើងទៅនៅចូលព្រៃ ៧៩-៨១ៗ

ដានី: កាលពី៧៩-៨១ កូនចៅ កូនទាហាន បើសិនមិនពេញចិត្តអ្នកណា?

ចំរើន: មិនពេញចិត្តអ្នកណាដូចមិនមានសួរនាំពីណាទេ យកគ្នាទៅវ៉ៃចោលបំបាត់កស្តុតាង តែបើឲ្យគាត់បញ្ជាពីលើមកខ្ញុំមិនដែលឃើញទេ វាខូចតែគំនុំគ្នាឯងហ្នឹងឯង ដែលស្លាប់ៗ ៗ

ដានី: ដល់ពេលឆ្នាំ៩៨ កងទ័ពតាម៉ុក ផ្តាច់ខ្លួនទៅ មីងរស់នៅណាទៅកាលហ្នឹង?

ចំរើន: ខ្ញុំនៅទំនប់ដាច់ ដល់ផ្តាច់ខ្លួនហើយខ្ញុំមកនៅហ្នឹងវិញដដែលៗ

ដានី: ម៉េចបានផ្លាស់ពីទំនប់ដាច់មកហ្នឹងវិញ? ដោយសារយើងមានផ្ទះនៅនេះ?

ចំរើន: ដោយសារយើងមានផ្ទះ មានដីធ្លីនៅនេះស្រេចហើយ ហើយវាមានផ្លូវស្រេច អីចឹងយើងមកនៅតាមដីយើង ផ្ទះយើងវិញទៅៗ

ដានី: ដល់ពេលមកដី មកផ្ទះ យើងរានឯង?

ចំរើន: យើងរានតាំងពីមុនមក ដីអ្នកណាអ្នកហ្នឹងយកវិញទៅៗ

ដានី: មីងបានដីច្រើនដែរ?

ចំរើន: មិនច្រើនទេ កាលនោះដូចជាមិនចង់បានផង យើងមិនគិតថាស្រុកគេដល់ប៉ុណ្ណេះ នឹកឃើញថានៅគ្នាឯងមិនដឹងយកដីទៅណាអស់ៗ

ដានី: គិតតែមួយរស់?

ចំរើនៈ ចា៎! គិតតែមួយរស់ ដីខ្ញុំបានក្បាលតែ៦០ម៉ែត្រជាង តែបណ្តោយប្រហែល១គីឡូដែរ នៅប៉ុណ្ណោះឯង ដីភូមិ អត់មានទឹកឃើញថា ។

ដានីៈ ហ្នឹងមីងដាំស្វាយ?

ចំរើនៈ ចា៎! ទៅក្រោយ តែដល់ឥឡូវក៏វាមិនច្រើនដែរប៉ុណ្ណឹង ដីចំការ៨-១០ហាត់គ្រាន់តែចែក កូន កូនច្រើនដែរ ។

ដានីៈ ឆ្នាំណាបានទៅលេងផ្ទះដំបូង?

ចំរើនៈ គេផ្តាច់ខ្ទួនហ្នឹងនិយាយពីយន្តហោះចុះ មួយថ្ងៃ១៨-៩គ្រឿង គេថាពីណាចង់ទៅលេងផ្ទះ ទៅៗ គេអត់យកលុយទេ យន្តហោះគេដឹកដល់ពោធិ៍ចិនតុង ខ្ញុំនឹកឃើញថាអត់ទៅទេខ្មាស់ គេណាស់ បាត់៣០ឆ្នាំហើយទៅវិញបាតដៃទទេ សុខចិត្តនៅរបស់នៅនេះ ។ ដល់ខែភ្ជុំ នឹក ឃើញចង់ទៅលេងផ្ទះ ទៅខ្ញុំទៅដើរ កាលហ្នឹងអត់មានផ្លូវទេ យើងនៅនេះចង់លក់ឥវ៉ាន់ ទៅយកពីសៀមរាបមក ក៏ទៅតាមផ្លូវហ្នឹង បរទេះ ។

ដានីៈ ដើរតាមព្រៃស្អាកហ្នឹង?

ចំរើនៈ ចា៎!

ដានីៈ ទៅដល់ផ្លូវ?

ចំរើនៈ ទៅនេះទៅ ព្រៃស្អាកហ្នឹង តាមអូរអាចម៍កុក អូរអាចម៍ចែរទៅធ្លាក់ថ្នាល់វន្ទះ ។

ដានីៈ ផ្លូវថ្នល់ជាតិគេធ្វើកាត់អន្លង់វែងហ្នឹង?

ចំរើនៈ ហ្នឹងហើយ ។

ដានីៈ ព្រោះជិះទៅមានគេដាក់ព្រៃស្អាក ។

ចំរើនៈ បើខាងនោះគេទៅតាមផ្លូវហ្នឹងឯង ផ្លូវព្រៃស្អាកហ្នឹងឯង យើងខាងនេះទៅផ្លូវកាត់លឿន ជាង អត់វៀង ។

ដានីៈ មីងដើរទៅ?

ចំរើនៈ ដើរខ្ញុំពរកូនខ្ញុំពៅហ្នឹងមួយ និងកូនស្រីមួយបណ្តើរទៅ ពីនេះទៅអូរអាចម៍ចែរ ពីនេះមួយ ថ្ងៃទៅដេកអូរអាចម៍ចែរ ដេកមួយយប់ហ្នឹងព្រលឹមឡើងចេញពីអូរអាចម៍ចែរហ្នឹងទៀត ទៅដេកស្រែចា ។

ដានីៈ ដើររហូត?

ចំរើនៈ ចា៎! អ៊ូ អាណិតកូនខ្ញុំពងជើងអស់ហើយអំណាចតែចង់ទៅស្គាល់ស្រុក ទៅដល់ស្រែចាដេក ស្រែចាមួយយប់ ចេញពីស្រែចាម៉ោង៣បានទៅដល់ថ្នាល់វន្ទះដល់ផ្លូវឡានគេមកពី សៀមរាប ដល់ម៉ុភ្នំ ។

ដានី៖ ដល់ម៉ោង៣ល្ងាច?

ចំរើន៖ ចា៎!

ដានី៖ ម៉ោង៣ល្ងាចបានឡានជិះ?

ចំរើន៖ ចា៎!

ដានី៖ ឆ្នាំណាហ្នឹង?

ចំរើន៖ ឆ្នាំដែលគេកំពុងធ្វើបាតុកម្មនៅមុខរដ្ឋសភាហ្នឹង យើងផ្ដាច់ខ្លួនហើយ៩៨ហ្នឹង ទៅគេកំពុងបាតុកម្ម ទៅដល់ភ្នំពេញគេថា គេពុលមិនហ៊ានហូប ខ្ញុំនឹកឃើញ៣០ឆ្នាំខ្ញុំមិនដែលស្គាល់ភ្នំពេញទេ ដល់ទៅម្ដងហ្នឹងមានអីជិះឡានពីថ្នាល់វង្វេះហ្នឹងទៅដេកនៅសៀមរាបមួយយប់ព្រលឹមឡើងឡានទៅភ្នំពេញ អ្នកឡានវានិយាយប្រវត្តិខ្មែរក្រហមផ្ដាច់ស្ពាននេះ ផ្ដាច់ផ្លូវតែតាមការពិតព្វខ្ញុំមួយឡានសុទ្ធតែខ្មែរក្រហមទាំងអស់ សុទ្ធតែអ្នកទៅពីត្រពាំងប្រាសាទចេះតែស្ដាប់តែកុងឡាននិយាយ ។ ទៅដល់ភ្នំពេញអត់មានបានជាន់ដីភ្នំពេញតិចទេ ចុះពីឡានឡើងម៉ូតូទៅផ្សារដើមគរហ្នឹងអ្នកឡានរញ៉េរញ៉ៃទាញគ្នា ហើយមួយសារហ្នឹងលឺថានេះពុល នោះពុលអត់ហ៊ានទិញអីឲ្យកូនហូបទេ ហើយកូនវាយំអើយយំ វានៅតូចៗ ។

ដានី៖ ហេវ?

ចំរើន៖ អត់ហេវទេ វាឃើញគេទាញចុះទាញឡើង ភ័យខ្លាចបាត់ម៉ែ បាត់កូន ឡានស្លាបលេងគេទៅផុតអស់ ក៏ជិះឡានតាកែវ ។ វាថាមីងជិះឡានខ្ញុំមកខ្ញុំទៅតាកែវផ្លូវជាតិលេខ៣ដូចគ្នានឹកឃើញថាទៅចុះនៅសង្កសីហើយ ដល់ពេលទៅដល់ផ្កាយរោងថ្ងៃហ្នឹងចែដន្យអីប៉ូលីសហើយទាហានវ៉ៃគ្នានៅផ្កាយរោងហ្នឹងទៀត ។ អ្នកយាម ហើយនិងទាហាន បាញ់គ្នាទុងទាំង ៗ ឡានហ្នឹងរត់កាត់ស្រែ ទៅធ្លាក់ណាយប់បានដល់សង្កសី វៀងកន្លែងគេបាញ់គ្នាចៃដន្យម្ល៉េះមកពីនោះសង្គ្រាមប៉ុន្មានឆ្នាំហើយ មកស្រុកមួយថ្ងៃហ្នឹងជួបគេវ៉ៃគ្នាទៀត ។ ខ្ញុំថាដូចកំសត់ណាស់ ទៅដល់សង្កសីសួរគេថាមានផ្ទះសំណាក់ដែរ អត់មានផ្ទះសំណាក់ទេបងឯងចង់សំរាកហ្នឹង បងឯងសុំផ្ទះគេទៅ ហើយខ្ញុំមានដាក់កាម៉េលដាំបាយឲ្យកូនមានកានទឹកទៅ យើងនៅព្រៃធ្លាប់ត្រៀម ដាក់ទៅ ។ ទៅដល់សង្កសីនឹកឃើញថាដេកហ្នឹងហើយម៉ូតូឌុបមកជាមួយ គេថាមីងទៅណា? ខ្ញុំថាខ្ញុំទៅស្លាបលេង មកខ្ញុំជូនទៅមីង ខ្ញុំថាអត់ទៅទេយប់ហើយខ្ញុំដេកនេះហើយ ថាអត់ទេ មីងឯងអាណិតខ្ញុំ ខ្ញុំអត់ទាន់បានម៉ូយមួយទេ ប្រពន្ធខ្ញុំកូនខ្ចីផងរកលុយទិញអង្ករអត់បាន ក៏ទៅឲ្យគេជូនទៅទាំងយប់ហ្នឹងទៀត ធម្មតា៣០ឆ្នាំហើយវាវង្វេង ។ គេថាមីងឯងនៅណា ខ្ញុំថានៅកំពង់ធំ ទៅលេងឪពុកខ្ញុំ អត់ហ៊ានប្រាប់គេថានៅត្រពាំងប្រាសាទទេ ព្រោះអីតំបន់ខ្មែរក្រហមថ្មីៗ ខ្ញុំនៅកំពង់ធំ ដល់ជិះម៉ូតូ

ទៅឃើញគេបាញ់កញ្ជួចភ្នំស្រង់ សួរគេថាអូនហ្នឹងភ្នំអី គេថាភ្នំស្រង់មីង ។ នឹកឃើញថា សួរគេថាធ្លាប់មកដែរ ភ្លេចភ្នំស្រង់ទៀត ដល់ទៅខ្ញុំចាក់ទឹកចោលហើយ មានលុយ មាស ប្រាក់តិចតួច ខ្ញុំដាក់ក្នុងកានទឹក នឹកឃើញថាភ្នំក្អែកទន់ហ្នឹងគេចំណាំប្ដូន់ គេខ្លាចហ្នឹងឯង ។ ជិះម៉ូតូទៅអត់អីទេ ទៅដល់ស្ពាបលេងគេសួរថាមីងឯងឈប់ផ្សារថ្មី ឬផ្សារចាស់? ខ្ញុំនឹក ឃើញកាលខ្ញុំមកអត់មានផ្សារថ្មី ផ្សារចាស់ទេ មានផ្សារតែមួយ ឥឡូវម៉េចមានថ្មី មាន ចាស់ ប្រាប់គេថាផ្សារចាស់តែម្ដងម៉េចៗជិតដល់ផ្ទះ ឈប់ផ្សារចាស់ ទៅដល់ផ្សារចាស់ ហើយណាផ្ទះមីង? ផ្ទះមីងណាបើខ្ញុំមិនដល់ផ្ទះខ្ញុំផង ដល់អីចឹងឲ្យគេរកផ្ទះសំណាក់នៅស្ពាប លេងហ្នឹងទៀត ថាអត់មានទេមីង អត់មានផ្ទះសំណាក់ អីចឹងអូនឯងជូនមីងឲ្យដល់ផ្ទះមីងឲ្យ ២ម៉ឺន ។ មីងអើយម៉ូតូខ្ញុំដាច់ភ្លើងបាត់ខ្ញុំទៅមិនរួចទេ ទៅសុំផ្ទះគេដេក បងខ្ញុំសុំផ្ទះសំណាក់ មួយយប់ គេថាអើយផ្ទះខ្ញុំគ្មានមុង គ្មានកន្ទេលទេ ខ្ញុំសុំតែសរសេរចងអង្រឹងឲ្យកូនខ្ញុំទេ មិនបាច់មុង មិនបាច់កន្ទេលទេ ។ សួរថាចុះផ្ទះគាត់នៅណាបានទៅអត់ដល់ ខ្ញុំថាខ្ញុំនៅ ផ្ទាល់ទ្រនន់ហ្នឹង ។ ចុះម៉េចបានទៅអត់ដល់? ខ្ញុំរកមិនឃើញមិនដឹងឯណា ដល់ស្រុកឯង បានហ៊ានប្រាប់គេថាខ្ញុំទៅពីអន្លង់វែង ខ្ញុំថាខ្ញុំបែកពីស្រុក៣០ឆ្នាំហើយ ខ្ញុំទើបមកម្ដងហ្នឹង មិនដឹងផ្ទះខ្ញុំនៅត្រង់ណាទេ ។ គេសួរថាកូនពីណា? ប្រាប់ទៅបានគេថាបងប្អូនឯងសោះ មុនដំបូងសុំគេ គេអត់ចង់ឲ្យដេកទេ ដល់ប្រាប់គេ គេថាខ្ញុំត្រូវបងប្អូនគាត់ដែរ អីចឹងខ្ញុំថាខ្ញុំ រកគាត់ជូនទៅផ្ទះបងខ្ញុំបន្តិច ។ បងខ្ញុំនៅផ្សារស្ពាបលេងហ្នឹងឯង បានទៅជួបបង ពុកខ្ញុំ ឡើងគាំង នឹកឃើញថាគ្មានរស់ទេ ៣០ឆ្នាំហើយ កូនគេប្រុសៗផងនៅបាត់អស់ ស្លាប់អស់ ហើយឯងស្រី ។

ដានី: ក្រែងបងមីងគាត់ទៅមុន?

ចំរើន: ចា៎! គាត់ទៅកាលជំនាន់អ៊ុនតាក់យើងឈប់វៃគ្នាមួយសារ ហើយដល់អ៊ុនតាក់ហើយវៃគ្នា មួយសារទៀត ។ អ៊ុនតាក់៩៣ ហើយ៩៨បានខ្ញុំផ្ដាច់ខ្លួន បានទៅស្រុកម្ដងដូចកើតម្ដង ទៀត ។

ដានី: ទៅលេងផ្ទះបានប៉ុន្មានថ្ងៃបានត្រឡប់មកវិញ?

ចំរើន: ខ្ញុំទៅឡើងកន្ទះខែបានបកមកវិញ មកដើរវង្វេងនៅស្រែណូយទៀត មកដល់ស្រែណូយ មានផ្លូវណាមកនេះទៀត យើងចុះដើរមកវិញ ដល់ស្រែណូយវង្វេងដេកផ្លូវ២យប់ទៀត បានដល់ផ្ទះ ថាវេទនាណាស់ ពរកូនទៀត ។

ដានី: ឆ្នាំ៩៨?

ចំរើន: ចា៎! ៩៨ យើងមិនទាន់មានផ្លូវណា៎ មានតែផ្លូវរទេះហ្នឹង ។

ដានី: ក្រោយៗមកទៀតធ្លាប់ទៅលេងផ្ទះទៀតអត់?

ចំរើន: ខ្ញុំទៅរាល់ឆ្នាំ ពុកខ្ញុំឈឺនេះខ្ញុំទៅមើលគាត់រហូតដល់គាត់ស្លាប់ ខ្ញុំធ្វើ៧ថ្ងៃហើយ ១០០ខ្ញុំទៅធ្វើទៀត ៣ឆ្នាំខ្ញុំទៅធ្វើឲ្យទៀត ទើបតែចប់ឆ្នាំនេះខ្ញុំទៅធ្វើកឋិនស្រុកហ្នឹងម្តង នឹកឃើញថាកុំឲ្យបាត់ឈ្មោះ បោះសំលេងពេកៗ

ដានី: គិតមើលស្ថានភាពការរស់នៅ កាលពីឆ្នាំបែកមកឆ្នាំ៩៨ មកដល់ឥឡូវប្រែប្រួលខុសគ្នាម៉េចទៅ?

ចំរើន: ប្រែប្រួល ស្រុកយើងនេះ?

ដានី: ស្រុកយើងនេះ ហើយយើងទៅស្រុក វាខុសប្លែកគ្នាម៉េច?

ចំរើន: ខុសហើយ បើកាលពី៩៨យើងអត់មានផ្សារ ហើយម្យ៉ាងយើងមានតែផ្ទះតូចៗ ដល់មកឥឡូវជីវភាពវាធូរធារ និយាយទៅស្រុកយើងនេះប្រជាពលរដ្ឋភាគច្រើនធ្វើរបរកសិកម្ម ហើយដីយើងនេះយើងធ្វើដំឡូង ធ្វើសណ្តែកបាន វារាងធូរធារដែរ ប្លែកច្រើន ដោយសារយើងមានផ្លូវ មានផ្សារ យើងធ្វើអីក៏វាអត់ទុញ ប្លែកច្រើនៗ ហើយបើទៅស្រុកខ្ញុំនោះដូចជាមិនប្លែកទេ ព្រោះដីតែប៉ុណ្ណឹង ហើយជីវភាពគ្នាមានតែធ្វើស្រែ ធ្វើចំការ មានមុខរបរប្លែកមានតែកូនចៅមករោងចក្រៗ

ដានី: ដូចថាមនោសញ្ចេតនាក្រុមគ្រួសារវិញ ដូចថាកាលពីមុន កាលពីនៅក្មេងយើងចេញមកប្រហែលជាអត់សូវបានទាក់ទងគ្នា យ៉ាងម៉េចដែលការនឹករលឹក ដល់ក្រោយមកយើងចាប់ផ្តើមភ្ជាប់ឆ្នាំ៩៨មកដល់ឥឡូវ ខុសគ្នាម៉េចដែរ?

ចំរើន: កាលមុនធម្មតាទេយើងកាលមុនបងប្អូនតែបែកយូរតែងតែមានការនឹករលឹកហើយ ដល់យូរពេកដូចខ្ញុំ៣០ឆ្នាំ គេភ្លេចថាយើងស្លាប់បាត់ហើយ ដល់ពេលយើងបានទៅជួបគ្នាអីចឹងនិយាយទៅបងប្អូនទើបតែជួបគ្នាកើតម្តងទៀត អរណាស់ ពេលដែលទៅជួបគ្នាម្តងៗមានបុណ្យ មានទាន សប្បាយរីករាយណាស់ ហើយចង់តែទៅ មិនថាតែខ្ញុំទេកូនចៅខ្ញុំស្រុកកំណើតនៅនេះក៏ចង់តែទៅស្រុកខ្ញុំៗ ទៅម្តងៗជួបជុំក្រុមគ្រួសារទៅវាសប្បាយ ស្រឡាញ់គ្នាអត់បេះឈ្មោះគ្នាបងប្អូនៗ

ដានី: មួយទៀតខ្ញុំចាប់អារម្មណ៍ត្រង់ថាមីង ថាទៅដំបូងពេលទៅខែភ្ជុំទេ?

ចំរើន: ចា៎! ខ្ញុំទៅខែភ្ជុំៗ

ដានី: ចុះពីមុនមកតាំងពីមីងចេញពីផ្ទះមក ទៅនៅមណ្ឌលគិរី ទៅនៅក្នុង ពេលភ្ជុំ ពេលចូលឆ្នាំយើងបានធ្វើដែលអត់?

ចំរើនៈ ខ្ញុំនិយាយទៅតាំងពីចេញពីផ្ទះ ម៉ែពុកខ្ញុំមិនដែលបានទទួលដំណឹងថាខ្ញុំនៅឯណា អត់សោះ គ្រាន់តែថាខ្ញុំ ទោះបីខ្ញុំនៅព្រៃក៏ដោយ ក៏ខ្ញុំអត់ដែលដាច់ដែរប្រពៃណីយើងខែភ្ជុំ ខែចូលឆ្នាំ ទោះបីយើងមិនមានលោក ក៏យើងតែងតែធ្វើចាស់ៗ តាមអ្នកចាស់ មានសីល មានធម៌

ដានីៈ ប៉ុន្តែយើងនៅចាំថ្ងៃខែ ដល់ពេលភ្ជុំយើងដឹងថាហ្នឹងភ្ជុំ ចូលឆ្នាំអីដឹងដែរ?

ចំរើនៈ ដឹង ។

ដានីៈ ដឹងតាមពីណា?

ចំរើនៈ ទោះបីយើងនៅអីចឹងក៏មានប្រតិទិន ឬយើងដឹងថាខែនេះជាខែភ្ជុំ យើងដឹងថាក្នុងមួយឆ្នាំ បើចូលឆ្នាំៗខែ៤ បើខែ៤ក្នុងថ្ងៃទី១៣-១៤ហ្នឹងឯង ហើយយើងអត់បានប្រារព្ធពិធីអីធំដុំ ទេ នៅក្នុងព្រៃដែលយើងហូបក្តួច ហូបដំឡូង តែដល់ថ្ងៃចូលឆ្នាំក៏នាំគ្នាសំរាកដែរ ខែចូល ឆ្នាំត្រូវមានអីទុំ មានភ្ញៀវ មានផ្កា នាំគ្នាទៅបេះយកមកហូប ឬក៏ផុង ស្គរ នាំគ្នារាំ លេងក្នុងព្រៃហ្នឹងទៅ ដឹងថាថ្ងៃណាជាថ្ងៃចូលឆ្នាំ ថ្ងៃណាភ្ជុំយើងដឹង ។

ដានីៈ ប៉ុន្តែកាលពីជំនាន់៣ឆ្នាំ ជំនាន់មីងនៅមណ្ឌលគិរី កាលហ្នឹងមានបានធ្វើអីចឹងអត់?

ចំរើនៈ អត់ទេ វាគ្រាន់តែចេះជំនាន់ហ្នឹងគេអត់មានគិតថា បើចូលឆ្នាំហ្នឹងយើងអត់មានវត្ត ក៏ប៉ុន្តែ យើងមានកម្មវិធី៣ថ្ងៃពេញហ្នឹងចូលឆ្នាំ យើងសប្បាយ ។

ដានីៈ កាលនៅមណ្ឌលគិរី?

ចំរើនៈ ចាំ! យើងនៅខ្មែរក្រហម នៅកោះញែកហ្នឹង នៅមណ្ឌលគិរី ។ បើថា៣ឆ្នាំ ចូលឆ្នាំ៣ថ្ងៃ គឺពេញ៣ថ្ងៃរហូតដល់៧ថ្ងៃទៀត គ្រាន់តែកម្មវិធីរាំវែកហ្នឹងឯង ។

ដានីៈ រាំវែកតែយើងអ្នកធ្វើការនៅហ្នឹង ឬក៏យ៉ាងម៉េច?

ចំរើនៈ ប្រជាពលរដ្ឋគាត់លេងតាមគ្នាគាត់ក្នុងភូមិ ក្នុងស្រុកហ្នឹងទៅ ហើយយើងតាមមន្ទីរ តាមក្រ សួងយើងធ្វើតាមមន្ទីរយើងហ្នឹងទៅ អត់ដែលដាច់ដែរ ។

ដានីៈ ដល់ពេលភ្ជុំ?

ចំរើនៈ ខែភ្ជុំយើងគ្រាន់តែវេចនំ វេចអន្សមហូបទៅ ។

ដានីៈ គេអត់ឲ្យយើងទៅផ្ទះ?

ចំរើនៈ អត់ទេ អត់មានបានទៅផ្ទះ បើគេនៅជិតគេចេះតែទៅ បើយើងឆ្ងាយយើងទៅណា ហើយម្យ៉ាងខាងនេះហ្នឹងសភាពអ្នកគ្រប់គ្រងផ្សេង ហើយខ្ញុំអ្នកគ្រប់គ្រងផ្សេង ដល់អីចឹង មិនដែលនឹកនារឿងទៅផ្ទះ គ្រាន់តែថាអត់ដាច់ទេ ទោះបីយើងមានប្តី មានប្រពន្ធហ្នឹងទៀត មក យើងវេចនំ វេចអន្សមហៅចាស់ៗសែន ធ្វើជាកម្មវិធីតូចៗសំរាប់ក្រុមគ្រួសារ ។

ដានីៈ កាលជំនាន់ហ្នឹងអត់មានលោកទេ?

ចំរើនៈ អត់មានលោកទេ ។

ដានីៈ មីងដឹងទេថាម៉េចបានគេអត់ឲ្យមានលោក អត់ឲ្យមានវិហារវត្ត?

ចំរើនៈ ខ្ញុំអត់ដឹងដែរកាលនោះ ព្រោះអីតាំងពីខ្ញុំចេញទៅបងខ្ញុំបន្ទស់គាត់បួសឡើង៨ឆ្នាំ ដល់ស្រុកគេអីចឹងគេឲ្យគាត់សឹក ក៏គាត់សឹកទៅ តាំងពីហ្នឹងមិនដែលមានលោកទៀតណា៎ តាំងពី៧៣មក ។

ដានីៈ តាមវិទ្យុ ដូចថាថ្នាក់ដឹកនាំគេមានដែលប្រកាស បុណ្យចូលឆ្នាំ បុណ្យប្រពៃណីជូនពរអីដូចខាងតាប៉ុល ពត ខាងអីផ្សេងៗទៀត?

ចំរើនៈ មានខែបុណ្យ ខែទាន ខ្ញុំថាបើយើងនៅតាមគ្រួសារអីចេះក៏ហូបចុកអត់បានដូចអីចឹងដែរនោះបើថាខែចូលឆ្នាំនិយាយពីបើកមិនដឹងជាម្ហូប នំនែក ស្ករ ទឹកត្រី អង្ករដំណើប ប៊ីចេង ទឹកដោះ សណ្តែក មិនដឹងយកទៅណាអស់ទេខែចូលឆ្នាំ ខែភ្ជុំ បើកហូបមិនអស់ទេ ។

ដានីៈ ពេលយើងមកនៅក្នុងព្រៃ?

ចំរើនៈ យើងនៅ១០០១ នៅលើភ្នំ ខែចូលឆ្នាំ ខែភ្ជុំគេបើកសំភារៈហូបមិនឈ្នះទេ ។

ដានីៈ តែកាលជំនាន់៣ឆ្នាំ កាលមីងនៅមណ្ឌលគិរីមានដែលលឺតាមទូរទស្សន៍ តាមវិទ្យុទេ?

ចំរើនៈ លឺអី ខែភ្ជុំ ខែចូលឆ្នាំ?

ដានីៈ ខែភ្ជុំ ខែចូលឆ្នាំ ថ្នាក់ដឹកនាំគេ?

ចំរើនៈ ធ្វើតា៎ គ្រាន់តែគេប្រារព្ធពិធីអត់មានលោក ធ្វើបុណ្យខួប ចូលឆ្នាំ ភ្ជុំ គេធ្វើជាប់ ដូចថាគេធ្វើអីចឹងជាកម្មវិធីជប់លាង អត់មានលោក តែគេធ្វើជាប់ហើយអត់ដាច់ទេ ។ ហើយថ្ងៃ ១០ ក៏គេត្រូវជប់លាងម្តង ថ្ងៃ២០ម្តង ថ្ងៃ៣០ម្តង ក្នុងមួយខែគេត្រូវមានកម្មវិធី៣ដង ។

ដានីៈ មីងពេលដែលយើងមកនៅតាមភ្នំ១០០១, ១០០៣ មានចាមមកនៅជាមួយដែរ? ជនជាតិចាម?

ចំរើនៈ មានដែលតែវាភាគតិច ភាគតិចណាស់អត់សូវមានឃើញទេ មានតិច ។

ដានីៈ ចាម យ៉ាងម៉េចគេមកនៅជាមួយយើងអត់មាន?

ចំរើនៈ កាលនោះគ្នាទោះបីចាមម៉េចក៏ដោយ ដល់ចូលមកនៅអីចឹងដូចជាចង់អត់ហ៊ានចេញខ្លួនថាខ្លួនចាម ជនជាតិចិនក៏អត់ហ៊ានថាខ្លួនជាចិន ដូចសំរបខ្លួនទៅតាមគេ ។

ដានីៈ បន្ទាប់ពីយើងផ្តាច់ខ្លួនមកឆ្នាំ៩៨ អីចឹងនៅស្រុកភូមិយើង យើងចាប់ផ្តើមមានវត្ត មានលោក ឬមិនទាន់ទេ ពេលដែលយើងផ្តាច់ខ្លួនមក?

ចំរើនៈ ផ្តាច់ខ្លួនមកមានរៀបចំវត្តខ្លួនឯងទៅ មានចាស់ទុំ ។

ដានី៖ វត្តនៅណា?

ចំរើន៖ វត្តត្រពាំងប្រាសាទនោះខ្ញុំទៅកសាងផ្ទាល់ហើយ ទៅត្រួសត្រាយធ្វើកុដិ ធ្វើសាលាទៅបាន លោកចុះមក ។

ដានី៖ ឆ្នាំណាដែលយើងចាប់ផ្ដើមមាន?

ចំរើន៖ ឆ្នាំ៩៩ ។

ដានី៖ កាលហ្នឹងយើងផ្ដួចផ្ដើម ដោយសារប្រជាជនយើងអ្នកផ្ដួចផ្ដើមធ្វើ ឬខាងអាជ្ញាធរគេចាប់ផ្ដើម? ដូចថាមានគំនិតមកជួបជុំប្រជាជនយើងដើម្បីធ្វើ បានន័យថាគំនិតផ្ដួចផ្ដើមពីអាជ្ញាធរ ឬពីខាងប្រជាជន?

ចំរើន៖ កាលពីដំបូងនៅត្រពាំងប្រាសាទយើង ដោយសារកន្លែងហ្នឹងមានប្រាសាទ ដល់មានប្រាសាទ អាជ្ញាធរស្រុកគាត់រៀបចំឲ្យបោសសំអាត ក៏ផ្ដួចផ្ដើមឲ្យធ្វើវត្តកន្លែងប្រាសាទហ្នឹង ហើយបើវត្តនេះ វត្តព្រៃស្អាកទើបតែកកើតបាន៨ឆ្នាំទេ ដោយសារមុនដំបូងហ្នឹងគ្រួសារខ្ញុំគាត់មេភូមិ គាត់ចង់ឲ្យមានសាលាឆទាន សុំដីមួយកន្លែងសំរាប់ធ្វើសាលាឆទាន សំរាប់ចាស់ៗសុំសីល ដល់ពេលយើងធ្វើកើត ប្រជាជនគាត់ចូលរួមឈើមួយគូប, មួយថ្នាន កើតជាសាលាហ្នឹងទៅ នៅនោះគេសុំច្បាប់ធ្វើវត្តនៅចុងភូមិ ដល់គេសុំច្បាប់ធ្វើវត្ត គេរត់ច្បាប់ហើយ គេមានលោកយកមកដាក់ហើយ លោកនៅហ្នឹងអត់កើត វាអត់ត្រូវគ្នាជាមួយអ្នកកសាងវត្ត ដូចថាគេចង់វត្តហ្នឹងផ្ដាច់មុខតែឯង មិនមានឲ្យប្រជាពលរដ្ឋចូលរួម គេចង់ថាខ្លួនគេបង្កើតវត្តខ្លួនឯង ដល់ពេលលោកហ្នឹងនៅអត់បាន ក៏ខ្ញុំគិតថាឥឡូវយើងមានសាលាឆទាន បើលោកគង់អត់បាន យើងសុំលោកមកគង់នេះមក ដល់ពេលលោកមកគង់នៅហ្នឹងយើងចាប់ផ្ដើមរៀបចំធ្វើវត្ត ប្រជាពលរដ្ឋក្នុងភូមិហ្នឹង គ្រាន់តែលោកនិមន្តភ្លាម ខ្លះដែក សង្កសី ឈើ ដូចសស្រាក់សស្រាំកើតជាវត្តហ្នឹងបានទៅ ។

ដានី៖ ឥឡូវប៉ុន្មានអង្គ?

ចំរើន៖ មុន៧អង្គ ឥឡូវនៅ៧អង្គដដែល ។

ដានី៖ មានប៉ុន្មានវត្តទៅ?

ចំរើន៖ ក្នុងឃុំត្រពាំងប្រាសាទនេះដូចជាវត្ត៧ហើយ ច្រើន ។

ដានី៖ រីកដុះដាលច្រើន?

ចំរើន៖ គ្រាន់តែឃុំត្រពាំងប្រាសាទនេះ វត្តត្រពាំងប្រាសាទ, ព្រៃស្អាក, អូរក្រូច, ទំនប់ខ្នុរ, ស្រែកណ្ដាល ៧វត្តគ្រាន់ក្នុងឃុំហ្នឹង ដល់វត្តច្រើនអីចឹងកសាងក៏វាអត់រីកចំរើនដែរ វាក្រ រីក វត្តច្រើន ។

ដានី៖ ដូចថាវត្តមួយក្នុងភូមិមួយ ប្រជាជនតាមលទ្ធភាពគាត់ ។

ចំរើន៖ តាមលទ្ធភាពគាត់ ប្រជាពលរដ្ឋធ្វើបាន ។

ដានី៖ លោកច្រើនគាត់មកពីចំងាយៗ មកគង់ហ្នឹង?

ចំរើន៖ ដំបូងលោកមកពីឆ្ងាយមកនៅ១-២អង្គ យូរៗមានកូនចៅយើងតាមហ្នឹងបួសទៅ ។

ដានី៖ ចុះសាសនាផ្សេងៗគេមានចូលមក ហើយប្រជាជនយើងចាប់អារម្មណ៍ចូលចិត្តអីដែរ?

ចំរើន៖ គេមកដែរខាងសាសនាយេស៊ូហ្នឹងគេមកបញ្ច្រៀតមកច្រើនដែរ តែឥឡូវយើងឃើញថាប្រជាពលរដ្ឋយើងខ្លះក៏បាក់ទៅហ្នឹងដែរ ។

ដានី៖ ជាពិសេសប្រជាពលរដ្ឋយើងដូចមីងអតីតអ្នកតស៊ូគាត់បាក់ទៅ ឬក៏អ្នកថ្មីៗមក?

ចំរើន៖ អត់ទេ អតីតតស៊ូមិនងាយទៅអីចឹងម៉ង មិនងាយតាមគេផ្តាស ។

ដានី៖ អត់ងាយតាម!

ចំរើន៖ អត់ងាយទេ ដូចថាបាក់នឹងសាសនាព្រះពុទ្ធហ្នឹងឯង ។

ដានី៖ សាសនាព្រះពុទ្ធៗហ្នឹង ហើយអ្នកទៅខាងគ្រិស្តច្រើនតែអ្នក?

ចំរើន៖ អ្នកមកពីចំងាយ ដូចថាគេមកគេមានខ្សែរយៈបងប្អូនគេ គេចូលទៅ ។

ដានី៖ អ្នកមកនៅក្រោយៗទេ?

ចំរើន៖ ចា៎! បើថាអ្នកខ្មែរក្រហមនៅនេះមិនងាយទេ អត់ទេ ។

ដានី៖ សាសនាព្រះពុទ្ធៗហើយ?

ចំរើន៖ ចា៎! ដូចជានយោបាយអីចឹងកាលពីមុនយើងធ្លាប់តែចាញ់គេ ធ្លាប់តែនៅព្រៃ ដល់ឥឡូវគេឲ្យសុខរស់នៅ មានតួនាទីភារកិច្ចបានសេចក្តីសុខ អត់ភ័យខ្លាច វាបាក់ទៅជ្រុបទៅខាងហ្នឹង វាអីចឹងឯង ។

ដានី៖ ដូចជីវភាពវិញបើគិតពីមីងកាលពីជំនាន់តស៊ូ កាលហ្នឹងយើងហូបចុកអត់ចាំបាច់ព្រួយទៅរកយើងមានរបប បើឥឡូវបន្ទាប់ពីយើងសមាហរណកម្មមក យើងត្រូវប្រឹងប្រែងខ្លួនឯងត្រូវរកខ្លួនឯង យើងគិតមើលទៅមួយណាស្រួលជាង? បើតាមមីងឆ្លងកាត់ទាំង២ ។

ចំរើន៖ ធម្មតាទេកាលណាដែលយើងរស់នៅ ដូចជាមន្ត្រីរាជការឥឡូវហ្នឹងអីចឹង តែយើងស៊ីប្រាក់ខែគេត្រូវតែបំពេញភារកិច្ចឲ្យគេ ពីមុនមកក៏អីចឹងដែរគេបើកឲ្យហូបចុកមែន ក៏ប៉ុន្តែវាជាការងារជាកាតព្វកិច្ចរបស់យើងហើយ យើងត្រូវតែទៅសមរភូមិ ត្រូវទៅចាក់ចំរូង យើងត្រូវបិទចំរូង ។ ដល់មកឥឡូវយើងរកស៊ីខ្លួនឯង យើងប្រកបធ្វើស្រែចំការខ្លួនឯងអាហ្នឹងខ្ញុំគិតថាធម្មតាទេ ប្រជាពលរដ្ឋតែប៉ុណ្ណឹងវាបរិបូរណ៍ណាស់ទៅហើយ ។ យើងមានសិទ្ធធ្វើអីៗតាមចិត្ត យើងអត់មានភ័យខ្លាចអី យើងដឹងតែរកស៊ី បើកសិករហ្នឹងធ្វើតែស្រែ ចំការ

បានទៅហូបចុកខ្លួនឯង វាអត់មានលំបាកថាចាំពឹងគេបើកថ្ងៃនេះ ថ្ងៃនោះអត់ទេ យើងដឹងតែយើងធ្វើបាន ថ្ងៃណាមានកំលាំងធ្វើទៅ ថ្ងៃណាហេវដេកក៏អត់មានអ្នកណាមកត្រូតយើងដែរ ។ ពីមុនមកធម្មតាទេយើងហូបរបស់ដែលគេបើកឲ្យយើងបំរើគេហើយ បានគេឲ្យយើង ។

ដានីៈ ប៉ុន្តែវាមានបញ្ហាមួយចំនួន តាមយោបល់មីង មីងគិតម៉េច ដល់ពេលយើងមកខ្លួនឯង វាមានពេលដែលយើងរកស៊ីខ្លួនឯង ពេលខ្លះមាន ពេលខ្លះក្រ អ្នកខ្លះមានច្រើន អ្នកខ្លះមានតិច ។ វាជៀសមិនផុតទេការលោភលន់ អ្នកខ្លះបានមានហើយ ចង់មាន មានបញ្ហារំលោភចេះចុះ អាហ្នឹងបើតាមមីង មីងយល់ម៉េចដែរ?

ចំរើនៈ ខ្ញុំយល់ឃើញអីចឹង ធម្មតាទេយើងកាលពីខ្មែរក្រហមផ្តាច់ខ្លួនមកនិយាយទៅបាតដៃទទេដូចគ្នា អាហ្នឹងខ្ញុំគិតថាអ្នកដែលរស់នៅតំបន់មូលដ្ឋាននេះទេ តែបើសិនណាគេខំប្រឹងប្រែងទៅគេមានបានអាហ្នឹងជារឿងមួយ ។ តែរឿងមួយទៀតអ្នកខ្លះក៏មានបានដោយសារញើសឈាមគេដែរ ដូចជាមន្ត្រីរាជការ ក៏វាភាគតិចដែរ ភាគច្រើនគេល្អ វាតែងតែមានហើយ វាមិនអត់ទេ កន្លែងមួយៗនោះ ។

ដានីៈ តែបើតាមយោបល់មីង មីងគិតថាមួយណាស្រួលជាងមួយណា? ដូចថាឥឡូវយើងមានសេរីភាព យើងធ្វើអីតាមចិត្តយើងតែវាមានបញ្ហាអសកម្ម ពីមុនមកយើងដឹងតែគេដាក់ការងារឲ្យធ្វើចេះៗយើងធ្វើហើយយើងបានហូបចុក ។

ចំរើនៈ ខ្ញុំបើនិយាយពីទស្សនៈរបស់ខ្ញុំ ខ្ញុំគិតថាបើយើងមានសេរីភាពវាប្រសើរជាង ម្យ៉ាងមិនថាតែកសិករទេ យើងមន្ត្រីរាជការហ្នឹងក៏ដោយគេរៀបចំវិមជ្ឈការ អីចឹងឲ្យថ្នាក់ក្រោមយើងរកតម្រូវការខ្លួនឯង យើងដាក់ណាដែលជាអទិភាពហ្នឹងជាការល្អហើយ មិនមែនថាបើពីលើមកថាបទបញ្ជាពីថ្នាក់ជាតិមកបញ្ជាថាឲ្យយើងត្រូវធ្វើនេះ ធ្វើនោះ អីចឹងការបញ្ជាហ្នឹងវាមិនចំតម្រូវការរបស់ប្រជាពលរដ្ឋទេ អីចឹងគាត់រៀបចំជាវិមជ្ឈការ ឬសហវិមជ្ឈការ ខ្ញុំថាល្អរាល់ថ្ងៃនេះ ដោយសារអីដោយសាររកតម្រូវការសំរាប់មូលដ្ឋានយើងខ្វះអី ឬខ្លួនយើងសំរាប់បុគ្គលថាខ្លួនយើងខ្វះអីក្នុងក្រុមគ្រួសារយើងហ្នឹង យើងត្រូវមានផែនការខ្លួនយើង ខ្ញុំថាអាហ្នឹងល្អជាង ។

ដានីៈ មួយទៀតទាក់ទងពី កាលពីមីងនៅតស៊ូ យើងនៅតាមព្រំដែន ការរាប់អានគ្នារវាងអ្នកនៅក្នុងអង្គភាពជាមួយ អ្នកដែលនៅជិតៗគ្នាមានការរាប់អានគ្នាយ៉ាងម៉េច បន្ទាប់ពីយើងសមាហរណកម្មហើយ ដូចថាពេលយើងមានផ្ទះខ្លួនឯង មានដី មានការប្រែប្រួលដូចថាការរាប់អានគ្នា ភាពជិតស្និទ្ធវាមានស្និទ្ធស្នាលដូចគ្នាពីមុនយ៉ាងម៉េច? ឥឡូវយ៉ាងម៉េច?

ចំរើនៈ បញ្ហាហ្នឹងខ្ញុំតែងចាប់អារម្មណ៍ដែរ ដោយសារកាលពីមុនយើងអត់ យើងឃ្លាន មិត្តភក្តិមានអី អត់អី ហៅគ្នាហូបចុកទៅវិញទៅមក ការរាប់អានរស់នៅនិយាយទៅអ្នកដែលនៅពីមុនមកមិនមានអ្នកណាមួយស្រុកកំណើតនៅនេះ ឬបងប្អូនទេ សុទ្ធតែអ្នកឆ្ងាយៗពីគ្នាដល់ពេលមកនៅយើងចាត់ទុកអ្នកហ្នឹងជាបងប្អូន អ្នកនៅជុំវិញជាសាច់ញាតិរបស់យើង ហ្នឹងជាការល្អម្យ៉ាង តែដល់ក្រោយនេះមកខ្ញុំមិនថាម៉េចទេ មិនថាគេ មិនថាខ្ញុំទេ ដល់ពេលមកសង្គមនេះយើងជាប់រវល់រកស៊ីរៀងៗខ្លួន ម្នាក់ៗចេះតែប្រឹងគេប្រឹងឯង វាបាត់អស់ការដើរលេងគ្នាទៅវិញទៅមក រាក់ទាក់ស្និទ្ធស្នាលនោះក៏វាថយចុះដែរ ដោយសារពីមុនមានការស្និទ្ធស្នាលដូចថាទៅស្រែ ទៅចំការ ដើរទៅហត់ចូលផ្ទះអ្នកនេះ ប្រូកប្រាជគេតិចទៅ។ ដល់ពេលឥឡូវដូចថាវាទំនើបដែរ ចង់ទៅចំការម៉ូតូរឹងទៅផុតទៅ មកវិញផុតមក វារាងរយោល ផ្នែកសាមគ្គីហ្នឹង ហើយក៏មិនមែនថាកាត់ចោលទាំងស្រុងអត់ទេនៅតែមានភាពសាមគ្គីជិតស្និទ្ធហ្នឹង គ្រាន់តែវារយោលជាងមុន វាអត់មានឱកាសអីទៅអង្គុយប្រូកប្រាជជជែកគ្នាលេងដូចមុនៗ ធម្មតាមុនយើងហូបអង្ករគេបើកយើងមានឱកាស បិទចំរូងជុំគ្នា ឬមានពេលទៅអង្គុយប្រូកប្រាជសួរសុខទុក្ខគ្នា។ ដល់ពេលឥឡូវនេះយើងធ្វើរៀងៗខ្លួនប្រឹងរៀងៗខ្លួន ចង់បានរៀងៗខ្លួនយើងអត់សូវមានឱកាសស្និទ្ធស្នាលគ្នាទេ ពេលជួបជុំគ្នាមានតែពេលបុណ្យទានហៅគ្នាជួបជុំគ្នា ឬពេលការកូនបានជួបគ្នា វាអត់បានដូចមុន ធម្មតាដូចខ្ញុំនិយាយអីចឹងហូបអង្ករគេវាមានឱកាស ដល់ពេលធ្វើខ្លួនឯងចង់បានរៀងៗខ្លួន។

ដានីៈ ចង់បានកាន់តែច្រើន?

ចំរើនៈ ចា៎! ចង់បានកាន់តែច្រើន។

ដានីៈ បានប៉ុណ្ណេះចង់បានប៉ុណ្ណោះទៀត?

ចំរើនៈ បានប៉ុណ្ណេះទៀតល្អ រកពេលដើរនិយាយគ្នាលេង សួរសុខទុក្ខគ្នាអត់ចង់បានដែរ។

ដានីៈ ពីមុនមកយើងប្រឹងយ៉ាងម៉េចនៅតែប៉ុណ្ណឹង?

ចំរើនៈ ចា៎!

ដានីៈ យើងធ្វើល្មមក៏ប៉ុណ្ណឹង?

ចំរើនៈ ចា៎! ធ្វើល្មមក៏ប៉ុណ្ណឹងដែរ ដល់ឥឡូវបើគេធ្វើច្រើនគេបានច្រើន ធ្វើតិចគេបានតិច។ ហើយសំរាប់អ្នកដែលអត់សូវចាប់អារម្មណ៍ តាំងពីជំនាន់ខ្មែរក្រហមក៏នៅតែក្រ មកជំនាន់នេះទៀតក៏នៅតែក្រ ក្ររហូត ជួយនោះជួយតាំងពីខ្មែរក្រហមក៏មិនមាន ជំនាន់នេះទៀតគេជួយអ្នកក្រក៏នៅតែមិនឡើង សំរាប់អ្នកមិនសូវចាប់អារម្មណ៍។

ដានី: បើសិនជាពួកគាត់វិញមានអារម្មណ៍យ៉ាងម៉េចដល់ពេលឃើញ ដូចថាការធ្លាប់នៅពីមុនមក មានរបបប្រហាក់ប្រហែលគ្នា ខុសៗគ្នាតិចតួច ដល់ឥឡូវបើកសេរីឲ្យយើងរក គាត់អត់សូវប៉ិន ដូចគាត់គិតផ្សេង យើងគិតផ្សេង គាត់រាងមើលទៅខុសគ្នា យើងឡើង គាត់នៅថយដដែល? អារម្មណ៍គាត់ម៉េចដែរ?

បំរើន: ខ្ញុំគិតថាអ្នកដែលអីចឹង គាត់មិនសូវជាចេះពិចារណាវែងឆ្ងាយផង បើសិនជាគាត់ចេះពិចារណាវែងឆ្ងាយនឹងគេ គាត់អាចនឹងមានសន្ទុះឡើងនឹងគេ ព្រោះគាត់មកនៅនេះតាំងពីមុនគេដែរ មានដីធ្លី មានទឹក ដល់រហូតមកឥឡូវអត់ដីធ្លី ចាប់បានគាត់លក់អស់ ជីវភាពកាន់តែចុះដុនដាប ហើយគាត់ច្រើនលេងល្បែងទៀត យើងលំបាកជួយគាត់ កាលណាយើងជួយទាល់តែម្ចាស់គេប្រឹងងើបដែរបានយើងលើកគេទៅរួច ចុះបើគេអត់ប្រឹងងើបយើងទៅជួយគេទាំងជិហរ ឲ្យអង្ករទៅហូបអង្ករអស់ទៅហើយ ឲ្យសម្ភារៈទៅយូរៗអត់លក់ហ្នឹងបាត់ចប់ យើងលំបាកជួយគាត់ដែរ អីចឹងអ្នកហ្នឹងនៅតែមានមិនថាកន្លែងណាៗទេ នៅតែមានអីចឹង

ដានី: បើទាក់ទងពីបងប្អូនមីងកាលពីមុន កាលយើងនៅសង្គ្រាមវាហាក់ដូចជាឆ្ងាយ ដល់ឥឡូវយ៉ាងម៉េចដែរ ខុសគ្នាយ៉ាងម៉េចដែរ ចង់ដឹងពីមនោសញ្ចេតនា ទាក់ទងពីភាពជិតស្និទ្ធវិញពីបងប្អូនបង្កើត ឪពុកម្ដាយអីកាលពីសម័យយើងនៅតស៊ូតាមព្រំដែន ហើយក្រោយមកសមាហរណកម្មហើយមានការខុសគ្នាម៉េចដែរ?

បំរើន: ឥឡូវខ្ញុំឃើញថាវាខុសគ្នាត្រង់ថាទោះបីជាយើងនឹកម៉េចក៏ដោយ ក៏យើងអត់បានជួបដែរ ទោះបីយើងនឹកចង់ទៅយ៉ាងម៉េចក៏មិនបានទៅ ចង់លឺម៉េចក៏មិនបានលឺ តែឥឡូវយើងស្រួល ដូចថាបងប្អូនយើងនឹកខ្លាំងបងប្អូនមនោសញ្ចេតនា យើងទៅស្អែកបានស្អែក ទៅខានស្អែកបានខានស្អែក ឬទូរស័ព្ទទាក់ទងគ្នាបានស្រួលៗ មនោសញ្ចេតនាក៏វាស្អិតជាងមុនដែរ វាទាក់ទងគ្នាបានញឹកញាប់ៗ

ដានី: មីងកាលពីជំនាន់យើងឆ្នាំ៧៥ ដូចថាយើងរវល់យើងកាត់ផ្ដាច់មនោសញ្ចេតនាពីឪពុកម្ដាយបងប្អូន ឬមានការអប់រំនយោបាយ ហាក់ដូចជាយើងមានអារម្មណ៍ផ្ដាច់មិនសូវនឹកនាមិនសូវគិតបងប្អូន ឬយ៉ាងម៉េច ខ្ញុំអត់សូវយល់ដែរ?

បំរើន: ដូចជាគេនិយាយថាសក់អ្នកណា ក្បាលអ្នកហ្នឹងៗ បើខ្ញុំគិតជាទស្សនៈរបស់ខ្ញុំទេ មិនមែនគេ ធម្មតាការអប់រំគេមិនដែលអប់រំឲ្យយើងអាក្រក់ទេ គេអប់រំឲ្យយើងល្អហើយ តែប៉ុន្តែហ្នឹងស៊ីសងលើគោលជំហររបស់យើងទេ អ្នកខ្លះគេអប់រំឲ្យចេះ កាត់ផ្ដាច់មនោសញ្ចេតនាទៅឆ្ងាយកុំឲ្យនឹករលឹកក្រុមគ្រួសារ ហ្នឹងជាការអប់រំរបស់គេមែន ដើម្បីកុំឲ្យយើងហ្នឹងមានមនោសញ្ចេតនា ធម្មតាតែមានអារម្មណ៍នឹកផ្ទះ នឹកបងប្អូន បំពេញការងារឲ្យគេវាមិនបាន

ល្អ ហើយបើនិយាយពីមនោសញ្ចេតនាវាតែងតែមាន ទោះបីបែកយូរប៉ុណ្ណាក៏ដោយក៏តែងតែនឹក តែយើងកាត់ធ្វើម៉េច យើងមើលទៅតាមកាលៈទេសៈ បើសិនជាយើងនឹកហើយយើងគិតថាចង់ទៅហើយបានទៅ អាហ្នឹងយើងគិតៗ បើគិតថាចង់ទៅហើយវាមិនបានទៅ អាហ្នឹងយើងមិនមែនថាមិនគិតទេ តែចេះតែទុកក្នុងចិត្តទៅមិនដឹងធ្វើម៉េចៗ

ដានី: ដូចថាពេលហ្នឹងយើងត្រូវមានភារកិច្ច ឬគេមិនអាចអនុញ្ញាតឲ្យយើងទៅៗ

ចំរើនៈ ហ្នឹងហើយៗ

ដានី: ឥឡូវយើងស្រួល យើងអាចចង់ទៅ យើងចង់នឹក យើងមានលទ្ធភាពខ្លួនឯងយើងធ្វើបានកាលនោះយើងពឹងផ្អែកលើគេ?

ចំរើនៈ ចា៎! ទោះបីយើងមានលទ្ធភាព យើងមានលុយ មានកាក់ថាសំរាប់ទៅមកបាន បើគេមិនឲ្យមកក៏យើងអត់ អីចឹងមិនថាមិនគិតទេ គិតដូចតែគ្នាហ្នឹង គ្រាន់តែថាការកាត់ចិត្តៗ

ដានី: ពាក់ព័ន្ធរឿងសាសនាក៏អីចឹងដែរ ដូចថាការពីសម័យហ្នឹងយើងរវល់ការងារ ឬការងាររវាងឆ្ងាយ ក៏យើងមិនសូវបានច្រើនៗ

ចំរើនៈ ចា៎! ហ្នឹងហើយៗ

ដានី: ដល់ឥឡូវយើងចង់ធ្វើស្មានណាៗ

ចំរើនៈ ចង់ធ្វើស្មានណាក៏បាន ស្រេចលើយើងមានលទ្ធភាពធ្វើ វាស្រួលត្រង់អីចឹង គ្រាន់តែថាយើងចង់ធ្វើបុណ្យ យើងមានលទ្ធភាពធ្វើ យើងចង់ធ្វើថ្ងៃណាក៏បាន បើដូចមុនខ្ញុំមិនបានទេម៉ែខ្ញុំស្លាប់ ខ្ញុំអត់បាននៅទេ ខ្ញុំចេញផុតហើយ លឺតែបងខ្ញុំនិយាយថាអូនអើយម៉ែយើងស្លាប់បងសុំអង្ករគេបានមួយកញ្ជើរមកធ្វើបុណ្យឲ្យ ហើយមានគេច្រណែនទៀត នឹកឃើញស្រណោះគាត់ៗ

ដានី: កាលជំនាន់ណាហ្នឹង?

ចំរើនៈ ជំនាន់យើង៣ឆ្នាំ ខ្ញុំចេញតាំងពីនោះមក ដល់ឪពុកខ្ញុំស្លាប់ ខ្ញុំធ្វើឲ្យបានពេញលេញ បរិបូរណ៍របស់គាត់ៗ

ដានី: ដូចថាតាសុន សេន មីងធ្លាប់ស្គាល់គាត់ច្បាស់ទេ?

ចំរើនៈ បើតាសុន សេន ខ្ញុំស្គាល់ បើប៉ុល ពត ខ្ញុំអត់ដែលបានស្គាល់ អត់ដែលជុំរៀនសូត្រជាមួយគាត់អត់ទេៗ បើសុន សេន ១អាទិត្យ ឬ១ខែគាត់ហៅយើងទៅបង្រៀនម្តងៗ

ដានី: អត្តចរិតគាត់យ៉ាងម៉េចដែរ?

ចំរើនៈ អត្តចរិតគាត់ស្លូតបូតណាស់ គាត់អត់ចេះគ្រញ៉េងគ្រញ៉ាងអីទេ គាត់រាបសារស្លូតបូតទន់ភ្លន់ជាមួយមហាជន ហើយគាត់មិនជាអ្នកដំកើងបុកទេតាហ្នឹងៗ ទៅរៀនជាមួយយើង

អង្គុយជុំគ្នាក្រោមដើមឈើ ដាក់បន្តក់ភ្លើងមួយភ្លក់ក្បែរហ្នឹងខ្វាចមូស ភ្លើងបន្តក់មិនថាថ្ងៃមិនថាយប់ទេគាត់ ។

ដានី៖ គាត់ខ្លាចមូស?

ចំរើន៖ ចា៎! ខ្លាចមូស ខ្លាចគ្រុនចាញ់ ។

ដានី៖ គាត់កាច ឬស្លូតមើលទៅចរិតគាត់?

ចំរើន៖ ស្លូតទេ គាត់អត់កាចទេសុន សេន ។ បើប៉ុល ពត ខ្ញុំអត់ដែលបាននៅជាមួយ ហើយក៏មិនដែលបានឃើញគាត់ដែរ គ្រាន់តែគេថាបញ្ញាប៉ុល ពត ឬនាំដូចយើងឥឡូវអីចឹង ដូចកត្តិព្រឹទ្ធបណ្ឌិតប៊ុន រានី អ្នកមកជាតំណាងៗចុះមកដល់នេះ ពាំនាំពាក្យសំដីគាត់ តែបើសុន សេន ហ្នឹងខ្ញុំបានទៅរៀនសូត្រជាមួយគាត់ញឹកញាប់ ។

ដានី៖ តាម៉ុក ស្គាល់គាត់ច្បាស់ទេ?

ចំរើន៖ តាម៉ុក ហ្នឹងខ្ញុំស្គាល់ គ្រាន់តែខ្ញុំអត់សូវបានរៀនសូត្រជាមួយគាត់ទេ ដូចថាពេលគាត់បើកសម្ភារៈ គាត់មកមើលយើងបានឃើញស្គាល់គាត់ ។

ដានី៖ អត្តចរិតគាត់យ៉ាងម៉េចដែលតាម៉ុក?

ចំរើន៖ តាហ្នឹងអត្តចរិតគាត់ឆេវឆាវ បើគាត់ប្រុងថាឲ្យអីយើង គាត់ថាឲ្យហើយឆាប់យកមក ក្រយកគាត់ដកទៅវិញឲ្យអ្នកផ្សេងទៀតហើយ គាត់ឆេវឆាវណាស់តាហ្នឹង ឃើញអីថាហ្នឹងបាំងៗតែម្ដង គាត់អត់បេះទុក ។ បើសុន សេន គាត់មានក្រមសីលធម៌ល្អណាស់ ។

ដានី៖ តាខៀវ សំផន, នួន ជា?

ចំរើន៖ ខ្ញុំអត់ដែលបានធ្វើការជាមួយគាត់ទេ ព្រោះអីប៉ែកខាងនេះមានតែសុន សេនទេ ប៉ែកខាង ១០០១ ។

ដានី៖ តាសុន សេន, តាម៉ុក ពេលដែរគាត់និយាយ គាត់មានដែលលើកនិយាយរឿងប្រពៃណីរឿងសាសនា គាត់មានដែលនិយាយទេ?

ចំរើន៖ សំខាន់គាត់និយាយរឿងប្រពៃណីខ្មែរយើង តាំងពីការស្លៀកពាក់ ហូបចុក និយាយទៅគាត់មិនចង់ឲ្យបាត់ប្រពៃណីខ្មែរទេ គាត់ចង់លើកកំពស់ លើកស្ទួយណាស់ហើយ តែរឿងសាសនាហ្នឹងដូចថាវាមិនថាគាត់បំបាត់ទេ តែគាត់មិនសូវចាប់អារម្មណ៍រឿងធ្វើបុណ្យ ធ្វើទាន មានតែកម្មវិធីជប់លាង មេទ្វិញ ឲ្យធ្វើបុណ្យខែភ្ជុំ និមន្តលោក អត់មានទេ ដឹងតែជប់លាង ខែភ្ជុំ ខែចូលឆ្នាំហ្នឹងសប្បាយទៅ បើកសម្ភារៈឲ្យហូបទៅ សំរាកទៅអត់ឲ្យធ្វើការអីទេ ដល់ខែហ្នឹង ។

ដានី៖ មីងនៅជាមួយតាសុន សេន ច្រើនជាងនៅជាមួយតាម៉ុក?

ចំរើនៈ ចា៎! តាម៉ុក ខ្ញុំទើបមកនៅក្រោយឆ្នាំ៩៣នេះហើយទេ ដោយសារខ្ញុំចុះមកនេះវានៅក្នុងតំបន់គាត់គ្រប់គ្រង ។

ដានីៈ ចុះពេលមីងចេញពី១០០១ មកនៅនេះ មិននៅក្រោមតាម៉ុក?

ចំរើនៈ ចា៎! ហ្នឹងហើយ មកនៅគ្រប់គ្រងរបស់តាម៉ុក មកនៅខាងនេះ ។

ដានីៈ តាំងពី៨៤-៨៥មក?

ចំរើនៈ ៨៤-៨៥ យើងនៅគ្រប់គ្រងរបស់គាត់មែន តែយើងនៅក្នុងដីគាត់មែន តែក្រោមការគ្រប់គ្រងរបស់សុន សេន នៅឡើយ គ្រាន់តែយើងមកនៅប៉ែកខាងនេះ ។

ដានីៈ អត់នៅឡូកឡំជាមួយគ្នាគាត់ទេ?

ចំរើនៈ អត់ទេ នៅក្រោមការគ្រប់គ្រងរបស់សុន សេន ទេ ។

ដានីៈ អ៊ីចឹងអ្នកដែលមកពីមុំ៣ មកនៅកន្លែងអូរត្រាវ ច្រើនតែមកពីមុំ៣ទេ?

ចំរើនៈ ចា៎!

ដានីៈ ស៊ឹងចាន់-អូរត្រាវ?

ចំរើនៈ សុទ្ធតែមកពីមុំ៣ហើយ ។

ដានីៈ នៅដីរបស់តាម៉ុក តែក្រោមការគ្រប់គ្រងសុន សេនទេ?

ចំរើនៈ ចា៎! ទើបតែអស់ពីសុន សេនទេ ។

ដានីៈ អស់ពីឆ្នាំណា?

ចំរើនៈ ក្រោយអ៊ិនគាក់ ។

ដានីៈ ក្រោយអ៊ិនគាក់ទេ?

ចំរើនៈ ចា៎! បាននៅ ការបើករបបហូបចុកនៅក្រោមគ្រប់គ្រងរបស់គាត់ ។

ដានីៈ មីងខ្ញុំដូចជាអស់សំនួរអីត្រូវសួរនាំមីងទៀតហើយ មីងមានអីចង់បន្ថែមអ្វីដែលខ្ញុំអត់បានសួរនាំទេ?

ចំរើនៈ មិនមានអីទេ ដូចជាអស់ដែរហើយ និយាយតាមការដែលនឹកឃើញ ការចងចាំ ។

ដានីៈ ខ្ញុំអរគុណមីងច្រើនដែលបានចំណាយពេលជិត២ម៉ោង ដែលផ្តល់បទពិសោធន៍ការរស់នៅរបស់មីង ឆ្លងកាត់តាំងពីជំនាន់តស៊ូ រហូតដល់យើងសមាហរណកម្មមកតាមរយៈបទពិសោធន៍ចែករំលែកមកដល់ខ្ញុំ ខ្ញុំអរគុណច្រើន ។

ចំរើនៈ ខ្ញុំនិយាយអ៊ីទាំងអស់ហ្នឹងក៏ខ្ញុំនិយាយអ៊ីដែលខ្ញុំជួបប្រទះដែរ ខ្ញុំបានជួបប្រទះជាក់ស្តែងកន្លងមក ខ្ញុំធ្លាប់ជួបអីខ្ញុំនិយាយហ្នឹងឯង តែប៉ុណ្ណឹងទេ ។

ដានីៈ អ៊ីចឹងខ្ញុំអរគុណច្រើន ។

ចប់